# ដំណើររឿង
# នៃសេចក្ដីសង្ឃឹម

## ការស្វែងរកការផ្គត់ផ្គង់ក្នុងផែនការរបស់ព្រះជាម្ចាស់

Good Soil
Evangelism & Discipleship

សៀវភៅណែនាំសម្រាប់គ្រូដោយឥតគិតថ្លៃ៖ www.GoodSoil.com/Resources

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 1
16/11/2021 08:56:47 AM



# ដំណើររឿងនៃសេចក្ដីសង្ឃឹម៖ ការស្វែងរកការផ្គត់ផ្គង់ក្នុងផែនការរបស់ព្រះជាម្ចាស់

ការកែសម្រួលលើកទី៨ នៅខែកក្កដា ២០២០

© 2007-2016 Good Soil Evangelism and Discipleship

Association of Baptists for World Evangelism
P.O. Box 8585
Harrisburg, PA 17105 USA
លេខទូរស័ព្ទ៖ ( 877 ) 959-2293

980 Adelaide Street South, Suite 34
London, Ontario N6E 1R3 CANADA
លេខទូរស័ព្ទ៖ ( 877 ) 690-1009

Story Art: Justinen Creative Group

Graphic Design: Miriam Ritchie Design
បកប្រែដោយ៖ លោក ឈាង បូរ៉ា
អ្នករៀបចំអត្ថបទភាសាខ្មែរ៖ លោក ទេព រ៉ូ

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកគ្រូ បាន គន់, លោកស្រី ថាវ ប៊ុនរី, លោក ខែម បូឡុង និងលោកស្រី ឡូញ ស្រីវឌ្ឍ, លោកស្រី ពូល វដ្ឋា, លោក ប៊ុន ដេត
thors: Wayne Haston & Ron Berrus

ISBN ៩៧៨-១-៩៥១៦៧២-១៣-៣

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាត ឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុក ក្នុងប្រព័ន្ធ ម៉ាស៊ីន កុំព្យូទ័រ, ឬចែកចាយ បន្តរួមបញ្ចូលទាំងការប្រើប្រាស់ ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថត ចម្លង, ការថត ទុកជាឯកសារ សំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់ កម្មសិទ្ធិដើម ដែលនៅប្រទេសអាមេរិកឡើយ។

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មីកែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ ( គកស ) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ ( គខប ) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ ( គគខ ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។

Email: Info@GoodSoil.com
Web: www.GoodSoil.com

Good Soil
Evangelism & Discipleship



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 2 16/11/2021 08:56:51 AM

# មាតិកា

## ដំណើររឿងនៃសេចក្តីសង្ឃឹមគឺជាដំណើររឿងដែលមានពេលវេលានិងទីតាំងពិត


សេចក្តីណែនាំអំពីព្រះគម្ពីរ និងដំណើររឿងបែបជារូបភាពធំ ........ ៤
សេចក្តីណែនាំសម្រាប់ការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាក្រុមសម្រាប់អ្នកដឹកនាំ ........ ៥
ផែនទីនៃទឹកដីបរិសុទ្ធ (កាណាន/ទីក្រុងប៉ាឡេស្ទីន) ........ ៧
ផែនទីនៅសម័យបុរាណខាងកើត ........ ៨
រូបភាពនៃរោងឧបោសថនៅទីរហោស្ថាន ........ ១០


## ដំណើររឿងនៃសេចក្តីសង្ឃឹមក្នុងព្រះគម្ពីរសញ្ញាចាស់


ព្រះដែលគង់នៅអស់កល្បជានិច្ច ........ ១២
ការបង្កើតផែនដី ........ ១៣
ការបង្កើតមនុស្សលោក ........ ១៤
ការធ្លាក់ចុះរបស់លូស៊ីហ្វើរ(អារក្សសាតាំង) ........ ១៥
ការដែលមនុស្សចាប់ផ្តើមប្រព្រឹត្តអំពើបាប ........ ១៦
ប្រភពនៃសេចក្តីស្លាប់ ........ ១៧
ក្តីសន្យាអំពីអ្នកដែលនឹងយកឈ្នះលើសាតាំង ........ ១៨
ការផ្គត់ផ្គង់ការបិទបាំង ........ ១៩
ការបណ្តេញចេញពីសួនច្បារអេដែន ........ ២០
ទឹកជំនន់ដ៏ធំ ........ ២១
សេចក្តីសន្យាទៅកាន់លោក អ័ប្រាហាំ ........ ២២
ការបូជាលោក អ៊ីសាក ........ ២៣
ការត្រាស់ហៅលោក ម៉ូសេ ឲ្យធ្វើជាអ្នកដឹកនាំ ........ ២៤
គ្រោះកាច និងបុណ្យរំលង ........ ២៥
ការដែលសាសន៍អ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទ ២៦
ក្រឹត្យវិន័យ១០ប្រការ ........ ២៧
រោងឧបោសថនៅទីរហោស្ថាន ........ ២៨
ពស់លង្ហិន ........ ២៩
ការសោយរាជ្យរបស់ស្តេច ដាវីឌ ........ ៣០
ទំនាយអំពីព្រះមេស្ស៊ីដែលនឹងយាងមក ........ ៣១


## ដំណើររឿងនៃសេចក្តីសង្ឃឹមបន្តចូលក្នុងព្រះគម្ពីរសញ្ញាថ្មី


ការប្រសូតរបស់ព្រះយេស៊ូវនៅភូមិណាសារ៉ែត.. ៣២
សេចក្តីល្បួងពីសាតាំង ........ ៣៣
ការប្រកាសរបស់លោក យ៉ូហាន-បាទីស្ទ ........ ៣៤
ការជួបអ្នកដឹកនាំសាសនាម្នាក់ ........ ៣៥
ការជួបស្ត្រីសាសន៍សាម៉ារីម្នាក់ ........ ៣៦
ការអះអាងរបស់ព្រះយេស៊ូវអំពីភាពជាព្រះ ........ ៣៧
សេចក្តីបង្រៀនអំពីស្ថាននរក ........ ៣៨
ការអស្ចារ្យរបស់ព្រះយេស៊ូវ ........ ៣៩
ការក្បត់ព្រះយេស៊ូវ ........ ៤០
ការកាត់ទោសព្រះយេស៊ូវដោយចៅក្រមអយុត្តិធម៌ ៤១
ការឆ្កាងព្រះយេស៊ូវ ........ ៤២
ការកែប្រែចិត្តរបស់ចោរម្នាក់ដែលកំពុងស្លាប់ ........ ៤៣
ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ ........ ៤៤
ការយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ ........ ៤៥
សាវ័ក ពេត្រុស ប្រកាសដំណឹងល្អ ........ ៤៦
ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវសម្រាប់អ្នកជឿ ........ ៤៧
ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវក្នុងនាមជាស្តេច ........ ៤៨
សេចក្តីវេទនាចុងក្រោយរបស់សាតាំង ........ ៤៩
វាសនាដ៏អាក្រក់សម្រាប់អ្នកមិនជឿ ........ ៥០
វាសនាដ៏មានសុភមង្គលសម្រាប់អ្នកជឿ ........ ៥១


## សេចក្តីពិតសំខាន់៨យ៉ាងដែលកើតចេញពីដំណើររឿងនៃព្រះគម្ពីរអំពីសេចក្តីសង្ឃឹម


ព្រះជាម្ចាស់—អ្វីដែលយើងរៀនបានអំពីព្រះអាទិកររបស់យើង ........ ៥២
មនុស្ស—អ្វីដែលយើងរៀនបានអំពីមនុស្ស ........ ៥៣
អំពើបាប—អ្វីដែលយើងរៀនបានអំពីការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ........ ៥៤
សេចក្តីស្លាប់—អ្វីដែលយើងរៀនបានអំពីទារុណកម្មសម្រាប់អំពើបាប ........ ៥៥
ព្រះគ្រីស្ទ—អ្វីដែលយើងរៀនបានអំពីព្រះយេស៊ូវគ្រីស្ទ ........ ៥៦
ឈើឆ្កាង—អ្វីដែលយើងរៀនបានអំពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ........ ៥៧
ជំនឿ—អ្វីដែលយើងរៀនបានអំពីការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ........ ៥៨
ជីវិត—អ្វីដែលយើងរៀនបានអំពីជីវិតដ៏នៅអស់កល្បជានិច្ច ........ ៥៩



## ដំណើររឿងនៃសេចក្តីសង្ឃឹមត្រាស់ហៅឲ្យមានការឆ្លើយតបដោយមានជំនឿផ្ទាល់ខ្លួន ...៦០





The Story Translaated In Khmer -15.02.2021-Ro 3.0.indd 3 16/11/2021 08:56:54 AM

# សេចក្តីផ្តើម




ព្រះគម្ពីរគឺជាសៀវភៅដ៏អស្ចារ្យបំផុតដែលធ្លាប់បាននិពន្ធឡើង។ សូមនឹកស្រមៃដូចនេះ៖ សៀវភៅទាំង៦៦កណ្ឌនៃព្រះគម្ពីរដែលបាននិពន្ធឡើងត្រូវបានសរសេរក្នុងអំឡុងពេលច្រើនជាង១៥០០ឆ្នាំ ដោយអ្នកនិពន្ធខុសៗគ្នាប្រមាណ៤០នាក់ ដែលតំណាងឲ្យយុគសម័យនៃប្រវត្តិសាស្ត្រជាច្រើន ពីតំបន់ខុសៗគ្នា ទស្សនៈនយោបាយ និងប្រពៃណីខុសៗគ្នា កម្រិតលើការសិក្សា ការងារ ប្រវត្តិគ្រួសារ និងបុគ្គលិកលក្ខណៈមនុស្សខុសៗគ្នា។ ចំណែកឯភាគមួយចំនួននៃព្រះគម្ពីរក៏ត្រូវបាននិពន្ធឡើងក្នុងបីភាសាខុសៗគ្នា និងលើបីទ្វីបខុសៗគ្នាដែរ។

សៀវភៅអស្ចារ្យនេះមានប្រមាណច្រើនជាង៥០០សាច់រឿងដែលមានរួមជិត៣០០០តួឯក។ ប៉ុន្តែ មានភាពស៊ីគ្នាយ៉ាងល្អពីដើមដល់ចប់ក្នុងដំណើររឿងខុសៗគ្នាទាំងអស់បែបជាដំណើររឿងដ៏ធំមួយ។ នេះគឺជាដំណើររឿងដែលមានការបើកឆាកក្នុងលក្ខណៈដែលគួរឲ្យទាក់ទាញចិត្ត មានគម្រោងសាច់រឿងយ៉ាងច្បាស់ និងយ៉ាងចាប់អារម្មណ៍ មានតួឯកស្មុលយ៉ាងខ្លាំងដែលគួរឲ្យចាប់អារម្មណ៍ មានតួឯកគាំទ្រខុសៗគ្នា និងឆើតឆាយ មានរឿងអាថ៌កំបាំងជាច្រើនដែលត្រូវបានបើកសម្តែងតាមរយៈដំណើរសាច់រឿង និងការបញ្ចប់ដ៏គួរឲ្យរំភើប។ ជាដំណើរការដែលចាប់ផ្តើមយ៉ាងល្អ ហើយបន្ទាប់មកបន្តទៅមុខដ៏គួរឲ្យភ័យខ្លាច ហើយនៅទីបំផុតក៏បានបញ្ចប់យ៉ាងល្អប្រសើរជាងអ្នកអានជាច្រើននាក់អាចនឹកស្មានទៅដល់ទៅទៀត។ ហើយលើចំណុចទាំងអស់នេះគឺថា នេះគឺជាដំណើររឿងដ៏ពិត។

ការអាន និងការសិក្សាព្រះគម្ពីរគឺស័ក្តិសមណាស់ ទោះបើថាលោកអ្នកមានការសង្ស័យអំពីអ្វីដែលលោកអ្នកគិតថាលោកអ្នកដឹងអំពីសារនេះ។ សៀវភៅនៃអក្សរសាស្ត្រនៃផែនដីដែលនៅស្ថិតស្ថេរនេះមានតំណែងយ៉ាងជាប់លាប់ក្នុងនាមជាសៀវភៅដែលលក់ដាច់ជាងគេនៅគ្រប់ទីកន្លែង និងប្រទេសជាច្រើនលើពិភពលោកនេះ។ ការមានចំណេះដឹងលើព្រះគម្ពីរគឺជាចំណុចដ៏សំខាន់មួយក្នុងការធ្វើជាបុគ្គលដែលមានការរៀនសូត្របានជ្រៅជ្រះ និងមានចំណេះដឹងទូទៅ។

អ្នកដែលស្គាល់ព្រះគម្ពីរយ៉ាងច្បាស់ និងដំណើររឿងដ៏ធំនៃព្រះគម្ពីរមិនមានការភ្ញាក់ផ្អើលទេក្នុងការដែលឃើញភាពល្បីល្បាញនៃសៀវភៅនេះ។ ពួកគេយល់អំពីមូលហេតុដែលអ្នកអានមានចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅចំពោះព្រះគម្ពីរពេលដែលពួកគេចាប់ផ្តើមសិក្សាអំពីដំណើររឿងដ៏ធំដោយមានការបើកចំហចិត្តគំនិត។ ព្រះគម្ពីរបានលើកឡើងអំពីតម្រូវការជាសកលសម្រាប់គ្រប់ពេលវេលា ហើយក៏បានផ្តល់ជូនអំពីការផ្គត់ផ្គង់យ៉ាងស្កប់ស្កល់សម្រាប់តម្រូវការនោះផងដែរ។ នេះពិតជា«*ដំណើររឿងនៃសេចក្តីសង្ឃឹម*» មែន—ដំណើររឿងនៃការដែលព្រះជាម្ចាស់បើកសម្តែងអំពីការផ្គត់ផ្គង់ដ៏អស្ចារ្យក្នុងផែនការរបស់ទ្រង់ក្នុងការប្រទានសេចក្តីសង្ឃឹមដែលនៅអស់កល្បជានិច្ចចំពោះមនុស្សគ្រប់ពេល និងគ្រប់ទីកន្លែង។

ដូចជាការពិតជាមួយនឹងអក្សរសាស្ត្រដែលមានគុណភាពខ្ពស់ផ្សេងៗទៀត លោកអ្នកក៏អាចយល់ព្រះគម្ពីរបានយ៉ាងល្អត្រឹមត្រូវ ហើយអាចឲ្យផ្តល់តម្លៃយ៉ាងខ្ពស់បាន ប្រសិនបើលោកអ្នកសិក្សាដោយយកចិត្តទុកដាក់ តាំងពីដើមដល់ចប់។ សៀវភៅសិក្សាព្រះគម្ពីរមួយនេះនឹងជួយលោកអ្នកធ្វើការនោះ។



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 4 16/11/2021 08:56:55 AM

# សេចក្តីណែនាំ

## គន្លឹះសម្រាប់សិក្សាផ្ទាល់ខ្លួន

- ចាប់ផ្តើមនៅឯហេតុការណ៍នៃដំណើររឿងនៅដើមទំព័រ១២ ហើយបន្តតាមគម្រោងរហូតដល់ចប់ក្នុងទំព័រ៥១។ ហើយបន្ទាប់មកសិក្សា «ស្ពាននៃជីវិតដែលរៀបតាមកាល» ក្នុងទំព័រ៥២-៥៩ ដែលសង្ខេបសេចក្តីពិតសំខាន់៨យ៉ាងដែលកើតចេញពីដំណើររឿងដ៏ធំនៃព្រះគម្ពីរ។
- ជាទូទៅវានឹងអាចជាជំនួយដល់លោកអ្នកក្នុងការត្រឡប់ទៅមើលផែនទីព្រះគម្ពីរក្នុងទំព័រ៧-៩ និងរូបភាពនៃរោងឧបោសថក្នុងទំព័រ១០។ ផែនទីនឹងផ្តល់ជូននូវការយល់ឃើញនៃទីកើតហេតុនៃដំណើររឿង ហើយរូបភាពនៃរោងឧបោសថនឹងជួយឲ្យលោកអ្នកយល់អំពីរបៀបដែលអស់អ្នកដែលស្វែងរកព្រះជាម្ចាស់ក្នុងសម័យមុនឃើញសេចក្តីសង្ឃឹមនៃព្រះគម្ពីរ។
- សូមអានសំណួរសិក្សា និងបទគម្ពីរសម្រាប់ព្រឹត្តិការណ៍នីមួយៗតាមការណែនាំការសិក្សា។ យើងបានបង្កើតសំណួរទាំងអស់នេះឡើង ដើម្បីជួយលោកអ្នកក្នុងការពិចារណាយ៉ាងល្អិតល្អន់លើដំណើររឿងបែបជារូបភាពធំនៃសៀវភៅដ៏ធំនេះ គឺព្រះគម្ពីរ ក្នុងពេលវេលាដ៏ខ្លីដែលមានកម្រិតល្មមសមគួរ។
- ប្រសិនបើលោកអ្នកមានសំណួរ សូមកុំឲ្យការនោះរារាំងលោកអ្នកឡើយ។ លោកអ្នកនឹងទទួលបានចម្លើយមួយចំនួនលើសំណួររបស់លោកអ្នក ខណៈពេលដែលលោកអ្នកបន្តក្នុងការសិក្សា។ សូមគ្រាន់តែអនុញ្ញាតឲ្យដំណើររឿងប្រាប់អំពីខ្លួនឯងចុះ។ ប្រសិនបើលោកអ្នកនៅមានសំណួរបន្ទាប់ពីលោកអ្នកបានបញ្ចប់ការសិក្សា សូមស្វែងរកចម្លើយតាមរយៈបុគ្គលណាម្នាក់ដែលស្គាល់ព្រះគម្ពីរច្បាស់ ឬក៏ទំនាក់ទំនងមកកាន់៖ Info@GoodSoil.com។
- សូមគិតអំពីដំណើររឿងព្រះគម្ពីរបែបជារូបភាពធំហាក់បីដូចជាដំណើររឿងអាថ៌កំបាំងមួយចុះ។  សូមស្វែងរកតម្រុយដែលបើកបង្ហាញបន្តិចម្តងៗអំពីទីកើតហេតុ ហើយចូរទទួលបានអំណរក្នុងការឃើញរូបភាពនៃការតានតឹងអំពីហេតុការណ៍ដែលទទួលបានដំណោះស្រាយ និងការដែលដំណើររឿងបើកបង្ហាញជាបន្តបន្ទាប់ក្នុងការយល់ឃើញយ៉ាងច្បាស់លាស់ចុះ។
- លោកអ្នកនឹងឃើញគន្លឹះសម្រាប់ការសិក្សាផ្ទាល់ខ្លួនមួយចំនួនទៀតនៅផ្នែកខាងក្រោម ទោះបើឯកសារនោះផ្តោតយ៉ាងខ្លាំងជាចម្បងលើការណែនាំសម្រាប់អ្នកដឹកនាំក្នុងការសិក្សាក៏ដោយ។
- ប្រសិនបើលោកអ្នកស្ម័គ្រចិត្តក្នុងការចែកចាយអំពីបទពិសោធន៍ខ្លួនក្នុងនាមជាអ្នកចូលរួមក្នុងការសិក្សានេះ សូមចូលទៅកាន់គេហទំព័រនេះ  ហើយប្រាប់យើងផង៖ www.GoodSoil.com

## សំណើសម្រាប់អ្នកដឹកនាំការសិក្សាជាក្រុម

ទោះបើថា *«ដំណើររឿងនៃសេចក្តីសង្ឃឹម»* គឺអាចសិក្សាបានដោយផ្ទាល់ខ្លួនក៏ដោយក៏ជាទូទៅវានៅមានឥទ្ធិពលច្រើនជាងក្នុងការការសិក្សាព្រះគម្ពីរដែលមានការណែនាំពីអ្នកដឹកនាំជាមួយនឹងអ្នកចូលរួមម្នាក់ឬក៏ក្រុមតូចនៃអ្នករៀនសូត្រដែរ។

- ក្នុងអំឡុងពេលសិក្សាព្រះគម្ពីរ សូមអានសំណួរសិក្សាព្រះគម្ពីរឲ្យឮ។ និងបទគម្ពីរនានា។វាជាជំនួយក្នុងការចែករំលែកឱកាសនៃការអានជាមួយនឹងសមាជិកក្នុងក្រុមសិក្សា។ សូមបង្កើតការសិក្សានេះឲ្យពិតជាមានការចូលរួមមែន ហើយនាំអ្នកចូលរួមដោយមានសកម្មភាពក្នុងការចូលរួមការសិក្សាផ្ទាល់ខ្លួននៃអត្ថបទព្រះគម្ពីរ។
- ដើម្បីបន្ថែមល្បឿននៅលើការសិក្សា សូមបង្កើតរបៀបដែលអ្នកចូលរួមអាចរកឃើញខគម្ពីរយ៉ាងឆាប់រហ័ស។ ជម្រើសមួយចំនួនមានដូចតទៅ៖

១. សូមត្រៀម ដោយថតចម្លងខគម្ពីរនៃអត្ថបទទាំងអស់ ដែលលោកអ្នកអាចចែកឲ្យពួកគាត់។
២. ផ្តល់ជូនដល់អ្នកចូលរួមនូវព្រះគម្ពីរដែលមានការបោះពុម្ពក្នុងឆ្នាំដូចៗគ្នា ដើម្បីឲ្យលោកអ្នកប្រើប្រាស់លេខទំព័រក្នុងការជួយពួកគាត់រកខគម្ពីរ។
៣. ក្នុងព្រះគម្ពីរទាំងនោះ សូមកត់សម្គាល់លើខគម្ពីរដែលលោកអ្នកនឹងប្រើប្រាស់ក្នុងអំឡុងពេលសិក្សា។

- សូមយល់ថា *«ដំណើររឿងនៃសេចក្តីសង្ឃឹម»* គឺត្រូវបានរៀបរៀងឡើង ដើម្បីអនុញ្ញាតឲ្យមានកម្រិតខុសៗគ្នាមួយចំនួននៃការសិក្សាព្រះគម្ពីរខ្លះពាក់ព័ន្ធនឹងកម្រិតខុសៗគ្នានៃការញែកពេលវេលា។ ជម្រើសមួយចំនួនមានដូចតទៅ៖
- ក្នុងករណីនៃការសិក្សាពី ១៥-៦០ នាទី៖ ចាប់ផ្តើមពីទំព័រ១២ ហើយបន្តដល់ទំព័រ៥១ សូមចង្អុលបង្ហាញលើរូបភាពនៃព្រឹត្តិការណ៍នីមួយៗ ហើយអាន



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 5 16/11/2021 08:56:55 AM

# សំណើសម្រាប់អ្នកដឹកនាំការសិក្សាជាក្រុម (បន្ត)

ប្រយោគសង្ខេបដែលទាក់ទងគ្នាជាមួយនឹងព្រឹត្តិការណ៍៤០យ៉ាងនៃព្រះគម្ពីរ ឬក៏សង្ខេបព្រឹត្តិការណ៍ក្នុងពាក្យពេចន៍ផ្ទាល់ខ្លួន។ ប្រសិនបើអ្នកចូលរួមបង្ហាញ ការចាប់អារម្មណ៍ក្នុងសាច់រឿងសូមពន្យល់ត្រួសៗអំពីរបៀប «ស្ពាននៃជីវិតដែលរៀបតាមកាល» មានភាពស៊ីគ្នាជាមួយនឹងដំណើររឿងព្រះគម្ពីរបែបជារូបភាពធំ ហើយសង្ខេបសេចក្ដីពិតសំខាន់៨យ៉ាង «ស្ពាននៃសេចក្ដីពិត» នៅក្នុងទំព័រ៥២-៥៩។ សូមជូនសៀវភៅ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»* មួយក្បាលម្នាក់ៗដល់អ្នកចូលរួម និងព័ត៌មានទំនាក់ទំនងរបស់លោកអ្នក។

- ក្នុងករណីនៃការសិក្សាពី ២-៦ ម៉ោង៖ សូមមើលហេតុការណ៍នៃដំណើររឿងទាំងអស់ ក៏ដូចជា «ស្ពាននៃជីវិតដែលរៀបតាមកាល» ប៉ុន្តែសូមគ្រាន់តែអាន និងពន្យល់លើខគម្ពីរមួយចំនួនដែលមានការសំខាន់បំផុតក្នុងការពន្យល់ដំណើររឿងជារូបភាពធំ។
- ក្នុងករណីនៃការសិក្សាពី១៤ម៉ោង ឬក៏ច្រើនជាងហ្នឹង៖ សូមប្រើប្រាស់សំណួរពិភាក្សាជាមួយនឹងព្រឹត្តិការណ៍ព្រះគម្ពីរនីមួយៗ សូមអានខយោងនៃព្រះគម្ពីរទាំងអស់ ហើយពន្យល់បន្ថែម និងបង្កើតសកម្មភាពរួមគ្នា តាមដែលចាំបាច់ ក្នុងការជួយឲ្យអ្នកចូលរួមមានការយល់ដឹងយ៉ាងពេញលេញលើដំណើររឿងបែបជារូបភាពធំ។
- ជម្រើសលាយឡំ៖ សូមប្រើប្រាស់ការលាយឡំជម្រើសខាងលើខ្លះៗដោយផ្ដោតទៅលើព្រឹត្តិការណ៍ ខគម្ពីរ សំណួរដែលទាក់ទងទៅនឹងចំណុចស្នូលនៃការសង្គ្រោះក្នុងដំណើររឿង។
- មុនពេលសិក្សា៖ ប្រសិនបើមានការប្ដេជ្ញាចិត្តល្អពីអ្នកចូលរួម សូមស្នើឲ្យពួកគាត់បំពេញការសិក្សាព្រះគម្ពីរមុនពេលមកសិក្សា។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយពេលវេលានៃការអានដែលនឹងកើតឡើងក្នុងអំឡុងពេលសិក្សាឲ្យមានការឆ្លើយលើសំណួរពិភាក្សាយ៉ាងជាប់រហ័ស និងមានពេញទៅដោយការគិតទុកជាមុន។
- សំណួរសិក្សានឹងនាំមកនូវប្រធានបទដដែលៗមួយចំនួនក្នុងការសិក្សា។ សូមស្គាល់ប្រធានបទទាំងនោះ ហើយផ្ដោតលើវាខណៈពេលដែលលោកអ្នកដឹកនាំការសិក្សា៖ ការផ្គត់ផ្គង់កន្លែងដ៏ស្រស់ស្អាតរបស់ព្រះជាម្ចាស់ ពូជរបស់ស្ត្រីដែលនឹងយកឈ្នះលើសាតាំង ចំណុចសំខាន់នៃសត្វចៀម និងការខ្ចាយឈាមរបស់វាដើម្បីអត់ទោសអំពើបាប សេចក្ដីសន្យារបស់ព្រះជាម្ចាស់ក្នុងការប្រទានពរដល់គ្រួសារទាំងអស់នៅលើផែនដីនេះតាមរយៈលោកអ័ប្រាហាំ ការដាក់ទារុណកម្មដ៏អស់កល្បជានិច្ចសម្រាប់សាតាំង និងអ្នកមិនជឿដែលមានសតិសម្បជញ្ញៈ នឹងស្ដេចមួយអង្គពីសាសន៍យូដាដែលនឹងសោយរាជ្យយ៉ាងអស់កល្បជានិច្ច។
- សូមទាញយកប្រយោជន៍ពីផែនទីព្រះគម្ពីរនៅទំព័រ៧-៩ ឲ្យបានច្រើននូវរាល់ចំណុចដែលអាចទទួលយកបាន។ ហើយវាក៏ជាចំណុចដ៏សំខាន់ដែរក្នុងការដែលលោកអ្នកប្រើប្រាស់រូបភាពរោងឧបោសថក្នុងទំព័រ១០ក្នុងពេលវេលាដ៏សមរម្យ ដើម្បីពន្យល់ឲ្យបានច្បាស់លាស់អំពីលក្ខណៈពិសេសៗ និងតួនាទីនៃរោងឧបោសថ។ សូមផ្ដោតយ៉ាងពិសេសលើអ្វីដែលកើតឡើងនៅជិតច្រកផ្លូវចូលនៃអាសនៈរោងឧបោសថដូចដែលមានពណ៌នានៅក្នុងកណ្ឌគម្ពីរលេវីវិន័យជំពូក១។
- សូមព្យាយាមប្រើប្រាស់ព័ត៌មាននៅក្រោមទំព័រសងខាងដើម្បីជួយឲ្យអ្នកចូលរួមផ្ដោតលើអ្វីដែលគាត់បានរៀនលើទំព័រទាំងពីរនោះអំពីព្រះជាម្ចាស់( ក្នុងវគ្គព្រះគម្ពីរសញ្ញាចាស់ ) និងអំពីព្រះយេស៊ូវគ្រីស្ទ ( ក្នុងវគ្គព្រះគម្ពីរសញ្ញាថ្មី )។ បង្រៀនផ្ដោតលើ និងពង្រឹងម្ដងហើយម្ដងទៀតអំពីសេចក្ដីពិតដូចដែលយើងអានតាមរយៈព្រះគម្ពីរ នោះយើងនឹងកាន់តែរៀនបន្ថែមទៀតអំពីព្រះជាម្ចាស់ និងព្រះយេស៊ូវគ្រីស្ទដែលជាព្រះរាជបុត្រារបស់ទ្រង់។
- សូមចៀសវាងចេញពីប្រធានបទដែលខ្វែងគំនិតគ្នាដែលមិនសំខាន់ចំពោះដំណើររឿងនៃសេចក្ដីសង្គ្រោះ ហើយដឹកនាំដោយផ្ដោតលើព្រះជាម្ចាស់ ព្រះយេស៊ូវ និងដំណើររឿងបែបជារូបភាពធំទូទៅវិញ។ ប្រសិនបើមានការខ្វែងគំនិតបែបនោះកើតឡើង សូមឲ្យអ្នកចូលរួមសរសេរនូវសំណួររបស់ពួកគាត់ចុះ ហើយលើកឡើងជាថ្មីម្ដងទៀតបន្ទាប់ពីលោកអ្នកបានបញ្ចប់ការសិក្សាសៀវភៅ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»*។
- សូមចៀសវាងចេញពីសេចក្ដីល្បួងដោយចង់បើកបង្ហាញនូវចម្លើយចំពោះអាថ៌កំបាំងនានាក្នុងសាច់រឿងមុនសាច់រឿងបើកបង្ហាញវា។ សូមអនុញ្ញាតឲ្យសាច់រឿងបើកបង្ហាញដើមទីហេតុកាល និងចៀសវាងពីការពន្យល់អំពីអ្វីដែលព្រឹត្តិការណ៍ក្នុងព្រះគម្ពីរសញ្ញាចាស់កំពុងតែចង្អុលបង្ហាញទៅកាន់ មុនវាទទួលបានការបំពេញ។ នេះគឺជាចំណុចដ៏សំខាន់ណាស់!
- បន្ទាប់ពីលោកអ្នកបានបញ្ចប់ការសិក្សាលើ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»* សូមប្រើប្រាស់ DVD *នៃសេចក្ដីសង្ឃឹម* ដើម្បីសង្ខេប និងរម្លឹកក្រុមរបស់លោកអ្នកអំពីអ្វីដែលលោកអ្នកបានសិក្សា។ លោកអ្នកអាចទាញយក DVD *នៃសេចក្ដីសង្ឃឹម*បានតាមរយៈគេហទំព័រ៖ www.thehopeproject.com.
- សូមទាញយកសៀវភៅណែនាំសម្រាប់អ្នកដឹកនាំដោយឥតគិតថ្លៃសម្រាប់សៀវភៅ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»* ចេញពីគេហទំព័រ៖ www. GoodSoil.com របស់ក្រុម Good Soil និងរៀនបន្ថែមទៀតអំពីប្រធានបទស្រដៀងៗគ្នា។ ហើយសូមផ្ដល់ជូនមតិយោបល់របស់លោកអ្នកទាក់ទងនឹងបទពិសោធន៍របស់លោកអ្នកក្នុងការប្រើប្រាស់សៀវភៅ*«ដំណើររឿងនៃសេចក្ដីសង្ឃឹម»*។



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 6 16/11/2021 08:56:55 AM

# ទីតាំងដែលដំណើររឿងកើតឡើង

## ទឹកដីបរិសុទ្ធ

### កាណាន/ប៉ាឡេស្ទីន

ដំណើររឿងនៃសេចក្តីសង្ឃឹមរបស់ព្រះគម្ពីរគឺជាដំណើររឿងដ៏ពិតអំពីមនុស្ស ទីកន្លែង និងព្រឹត្តិការណ៍ដ៏ពិត។ ព្រឹត្តិការណ៍នៃដំណើររឿងនេះបានកើតឡើងក្នុងពេលវេលា និងលំហអាកាសលើផែនដីនេះយ៉ាងពិតប្រាកដ។

---

ទីតាំងកណ្តាលឆាកសម្រាប់ប្រវត្តិសាស្ត្រព្រះគម្ពីរគឺជាកន្លែងដែលរូបភាពនេះពន្យល់អំពីមជ្ឈឹមបូព៌ា។ សព្វថ្ងៃនេះយើងហៅថាទឹកដីសន្យា ប៉ុន្តែ ក្នុងសម័យដើមព្រះគម្ពីរហៅថាកាណាន ហើយក្រោយមកហៅថាប៉ាឡេស្ទីន។ នេះគឺជាដីឡូត៍ដ៏តូចល្មមដែលមានទំហំប្រមាណជាង២៤០គីឡូម៉ែត្រពីទិសខាងជើងទៅទិសខាងត្បូង និង១២០គីឡូម៉ែត្រពីទិសខាងកើតទៅទិសខាងលិច ប៉ុន្តែព្រឹត្តិការណ៍ដែលបានកើតឡើងនៅកន្លែងនេះជាច្រើនសតវត្សមុននៅតែផ្តល់ជូនទូវក្តីសង្ឃឹមដល់យើងនៅសព្វថ្ងៃនេះដែរ។






The Story Translaated In Khmer -15.02.2021-Ro 3.0.indd 7 16/11/2021 08:56:57 AM

# ផែនទីនៅសម័យបុរាណខាងកើត

ដូចដែលរូបភាពក្នុងទំព័រ៧បានពន្យល់អំពីទឹកដីសន្យា នោះគឺជាទីតាំងកណ្តាលឆាកសម្រាប់ព្រឹត្តិការណ៍ដ៏សំខាន់។ ក្នុង «ដំណើររឿងនៃសេចក្តីសង្ឃឹម» តំបន់ទូលំទូលាយនេះគឺជាទីកន្លែងឈុតឆាកបន្ថែមដែលមានព្រឹត្តិការណ៍នានានៃព្រះគម្ពីរជាច្រើនទៀតដែលបានកើតឡើង។ ប្រវត្តិវិទូហៅទីនេះថាទឹកដីសម័យបុរាណខាងកើត ប៉ុន្តែសព្វថ្ងៃនេះ យើងស្គាល់វាថាមជ្ឈឹមបូព៌ា។ តំបន់ពីកាណានទៅខាល់ដេក្នុងផែនទីដែលមានពណ៌បៃតង គេធ្លាប់ហៅវាថាដីមានជីវជាតិ ពីព្រោះដីនៅទីនោះអាចធ្វើកសិកម្មដាំដុះបាន។






The Story Translaated In Khmer -15.02.2021-Ro 3.0.indd 8
16/11/2021 08:56:59 AM




មុនលោកអ្នកចាប់ផ្ដើមសិក្សាសៀវភៅ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»* វានឹងកាន់តែជាជំនួយដល់លោកអ្នកក្នុងការដែលលោកអ្នកយល់ជាទូទៅអំពីតំបន់នេះសិន។ ខណៈពេលដែលលោកអ្នកបន្តក្នុងការសិក្សា នោះលោកអ្នកនឹងទំនងជាចង់ត្រឡប់មកមើលផែនទីទាំងនេះវិញ ដើម្បីរកទីកន្លែងមួយចំនួនដែលព្រឹត្តិការណ៍ដ៏សំខាន់ៗខ្លះបានកើតឡើង។



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 9 16/11/2021 08:57:00 AM

# រោងឧបោសថ

របនាសម្ព័ន្ធដ៏គួរឲ្យចាប់អារម្មណ៍នេះមានតួនាទីយ៉ាងខ្លាំងក្នុងពាក់កណ្ដាលនៃចំណុចដំបូងនៃ *«ដំណើររឿងនៃសេចក្ដីសង្ឃឹម»*។

ក្នុងការសិក្សាពេលក្រោយ លោកអ្នកនឹងទទួលបានការណែនាំឲ្យត្រឡប់មកមើលរូបភាពនេះ ដើម្បីរៀនអំពីមូលហេតុ និងរបៀបដែលរោងឧបោសថដែលអាចរើបានមួយនេះ ក្លាយជាសញ្ញាសំគាល់នៃសេចក្ដីសង្ឃឹម និងសេចក្ដីសន្យា សម្រាប់អស់អ្នកដែលស្វែងរកព្រះជាម្ចាស់ ដែលបានរស់នៅជាយូរឆ្នាំនោះ។




## លក្ខណៈពិសេសនៃរោងឧបោសថ

( គំនូរមិនបង្ហាញរង្វាស់ដ៏ពិតទេ )

១.មាត់ទ្វារទីលាន
២. របងទីលាន
៣. អាសនាលង្ហិន
៤. យញ្ញបូជានៅឯអាសនា
៥. ចានក្លាំលង្ហិន
៦. រោងឧបោសថ
៧. ទីបរិសុទ្ធ
៨. ជើងចង្កៀងមាស
៩. តុនៃនំបុ័ងតាំងទុក
១០. អាសនាគ្រឿងក្រអូប
១១. វាំងនន
១២. ទីបរិសុទ្ធបំផុត
១៣. ហឹបនៃសេចក្ដីសញ្ញា
១៤. ទីសណ្ដោសមាស
១៥. បង្គោលភ្លើង & ពពក



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 10 16/11/2021 08:57:04 AM

# ដំណើររឿង
# នៃសេចក្ដីសង្ឃឹម



ក្នុងទំព័របន្តបន្ទាប់ លោកអ្នកនឹងចាប់ផ្ដើមសិក្សាយ៉ាងចាប់អារម្មណ៍ជាខ្លាំងអំពីផែនការគោលរបស់ព្រះជាម្ចាស់សម្រាប់ចក្រវាលភពវិញ្ញាណ និងមនុស្សជាតិ។ លោកអ្នកនឹងរៀនអំពីចម្លើយលើសំណួរដ៏សំខាន់ៗដែលជាសំណួរដ៏សាមញ្ញចំពោះមនុស្សប្រុសស្រីសម្រាប់រាល់ពេលវេលា និងគ្រប់ទីកន្លែង៖ តើខ្ញុំបានមកដល់ទីនេះដោយរបៀបណា? តើអ្វីទៅជាអត្ថន័យនៃជីវិត? តើខ្ញុំអាចស្គាល់អត្ថន័យនោះនៅក្នុងជីវិតខ្ញុំដោយរបៀបណា? តើមានអ្វីកើតឡើងបន្ទាប់ពីខ្ញុំស្លាប់ទៅ? តើខ្ញុំអាចត្រៀមខ្លួនដើម្បីស្លាប់ដោយរបៀបណា?

*សូមបើកទំព័រ ហើយចាប់ផ្ដើមបទពិសោធន៍របស់លោកអ្នកជាមួយនឹងការបើកបង្ហាញដ៏ពិត និងរំភើបនៃ «ដំណើររឿងនៃសេចក្ដីសង្ឃឹម»។*



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 11
16/11/2021 08:57:08 AM

១ ក្នុងប្រយោគផ្ដើម ព្រះគម្ពីរបានលើកឡើងអំពីចំណុចមូលដ្ឋានគ្រឹះបំផុតនៃជីវិតមនុស្សជាតិ ដោយអះអាងថាអ្វីមួយ ឬក៏បុគ្គលណាម្នាក់ដែលមានជីវិតដ៏នៅអស់កល្បជានិច្ចគឺជាព្រះជាម្ចាស់។



# កាលដើមដំបូងឡើយព្រះ...

## ព្រះដែលគង់នៅអស់កល្បជានិច្ច

លោកុប្បត្តិ ១:១

ក. ហេតុអ្វីបានជាវាជាមូលហេតុសមរម្យក្នុងការសន្មតថាមានអ្វីមួយ ឬក៏បុគ្គលណាម្នាក់ដែលមានជីវិតដ៏នៅអស់កល្បជានិច្ច?

ខ. សូមអានឃ្លាដំបូងក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ១:១។ តើចំណុចមួយណាជាចំណុចពិត? សូមពន្យល់មូលហេតុរបស់លោកអ្នកក្នុងការជ្រើសរើស។

- ☐ *ព្រះគម្ពីរចាប់ផ្ដើមដោយព្យាយាមផ្ដល់ជាភស្តុតាងអំពីព្រះជន្មរបស់ព្រះជាម្ចាស់។*
- ☐ *ព្រះគម្ពីរចាប់ផ្ដើមដោយសន្មតថាព្រះជាម្ចាស់មានព្រះជន្ម។*

គ. សូមអានកណ្ឌគម្ពីរ ទំនុកតម្កើង ៩០:២។ តើឃ្លាថាមានព្រះជាម្ចាស់ «ចាប់តាំងពីអស់កល្ប រហូតដល់អស់កល្ប» មានន័យយ៉ាងដូចម្ដេច?

ឃ. ខណៈពេលដែលយើងអានព្រះគម្ពីរ នោះយើងនឹងកាន់តែរៀនបន្ថែមទៀតអំពីព្រះជាម្ចាស់—ថាទ្រង់ជានរណា ហើយមានលក្ខណសម្បត្តិដូចម្ដេច។ នៅក្រោមទំព័រសងខាងនីមួយៗ (ដែលមានលក្ខណៈដូចនេះក្នុងទំព័រ១២-១៣) សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងពីរ។

ង. ក្នុងភាសាហេប្រឺ ពាក្យព្រះដែលបានប្រើប្រាស់ឡើងគឺ «*អិលឡូហ៊ីម*» “elohim” ដែលមានន័យថា «អ្នកខ្លាំង»។

### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្ដា ☐ មានពេញទៅដោយអំណាច ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌
☐ ព្រះដែលការពារមានពេញទៅដោយសេចក្ដីមេត្តាករុណា
☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្ដីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 12 16/11/2021 08:57:09 AM

២

ព្រះគម្ពីរបានបន្តលើកឡើងថា ព្រះជាម្ចាស់បានបង្កើតចក្រវាលទាំងមូលរួមទាំងផែនដី និងផ្ទៃមេឃរបស់យើង ក៏ដូចជារបស់សព្វសារពើដែលមានជីវិត—រុក្ខជាតិ និងសត្វគ្រប់ប្រភេទ។



## ការបង្កើតផែនដី

*លោកុប្បត្តិ ១:១-២៥*

ក. ថ្ងៃទី១នៃការបង្កើត—សូមអាន១១-៥។

- ក្នុងគ្រាដំបូងនៃការបង្កើត (១២) តើផែនដីមានលក្ខណៈយ៉ាងដូចម្ដេច?
- តើព្រះជាម្ចាស់បានធ្វើអ្វីក្នុង១៣-៥?

ខ. ថ្ងៃទី២នៃការបង្កើត—សូមអាន១៦-៨។ តើព្រះជាម្ចាស់បានបែងចែកអ្វីនៅថ្ងៃនោះ?

គ. ថ្ងៃទី៣នៃការបង្កើត—សូមអាន១៩-១៣។

- តើមានអ្វីបានកើតឡើងមុនគេបង្អស់នៅថ្ងៃទី៣? *(សូមមើល១៩-១០)*
- តើមានអ្វីបានកើតឡើងជាបន្ទាប់នៅថ្ងៃដូចគ្នា? *(សូមមើល១១១-១៣)*

ឃ. ថ្ងៃទី៤នៃការបង្កើត—សូមអាន១១៤-១៩។ តើគោលបំណងមួយចំនួនរបស់ព្រះជាម្ចាស់សម្រាប់ផែនដីទាក់ទងនឹងពន្លឺលើផែនដីមានអ្វីខ្លះ?

ង. ថ្ងៃទី៥នៃការបង្កើត—សូមអាន១២០-២៣។ តើព្រះជាម្ចាស់បានបង្កើតសត្វអ្វីនៅថ្ងៃនោះ?

ច. ថ្ងៃទី៦នៃការបង្កើត ផ្នែកទី១—សូមអាន១២៤-២៥។ តើព្រះជាម្ចាស់បានបង្កើតសត្វអ្វីជាបន្ទាប់?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្ដល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស
☐ ព្រះដែលសម្ដែងសេចក្ដីពិត



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 13 16/11/2021 08:57:09 AM

៣ បន្ទាប់មក ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រី (លោក អ័ដាម និងនាង អេវ៉ា) ហើយបានផ្តល់ភារកិច្ចដល់ពួកគេក្នុងការមើលខុសត្រូវលើការបង្កើតផែនដីរបស់ទ្រង់ ប៉ុន្តែបានហាមមិនឲ្យពួកគេបរិភោគផ្លែឈើពីដើមឈើមួយ។



## ការបង្កើតមនុស្សលោក

*លោកុប្បត្តិ ១:២៦-៣១;*
*លោកុប្បត្តិ ២:៧-២៥*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១:២៦-២៧។ ពេលប្រៀបធៀបជាមួយនឹងរបស់សព្វសារពើផ្សេងៗទៀតដែលព្រះជាម្ចាស់បានបង្កើតមក តើមានចំណុចពិសេសអ្វីខ្លះអំពីការបង្កើតមនុស្សប្រុស និងមនុស្សស្រី?

ខ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១:២៨-៣១។ តើព្រះជាម្ចាស់បានផ្តល់តួនាទីពិសេសអ្វីទៅកាន់ពួកគេដែលព្រះអង្គមិនបានផ្តល់ទៅកាន់របស់សព្វសារពើផ្សេងៗទៀតដែលទ្រង់បានបង្កើតមក?

គ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២:៧។ តើយើងរៀនបានចំណុចពិតអ្វីបន្ថែមទៀតនៅទីនេះទាក់ទងនឹងការបង្កើតលោក អ័ដាម?

ឃ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២:៨-៩។ តើយើងឃើញមានចំណុចសម្គាល់អ្វីក្នុងខទាំងនេះដែលថាសួនច្បារអេដែនជាកន្លែងដ៏ស្រស់ស្អាត ហើយមានពេញទៅដោយផលផ្លែដែលមានសុភមង្គល?

ង. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២:១៥-១៧។ តើព្រះជាម្ចាស់បានបង្គាប់ចំណុចអ្វីមួយទៅកាន់លោក អ័ដាម ថាកុំឲ្យធ្វើ ហើយថា តើព្រះជាម្ចាស់បានមានព្រះបន្ទូលថានឹងមានអ្វីកើតឡើងប្រសិនបើមិនស្តាប់តាមបញ្ញត្តិមួយនេះ?

ច. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២:១៨-២៥។ **ពិត ឬមិនពិត?** *នៅពេលនោះលោក អ័ដាម និងនាង អេវ៉ា កំពុងរស់នៅក្នុងស្ថានភាពដែលគ្មានទោស។* តើលោកអ្នកឃើញអ្វីនៅក្នុងខគម្ពីរទាំងនេះដែលនាំឲ្យលោកអ្នកឈានដល់ការសន្និដ្ឋានបែបនេះ?



សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្តា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្តីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្តីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 14 16/11/2021 08:57:09 AM

៤ ក្នុងអំឡុងពេលមុន ពីដើម លូសេហ្វឺរគឺជាទេវតាដ៏ស្រស់ស្អាតម្នាក់របស់ព្រះជាម្ចាស់។ វាក៏បានដឹកនាំទេវតាផ្សេងទៀតក្នុងការបះបោរប្រឆាំងនឹងព្រះជាម្ចាស់ដោយបរាជ័យ ហើយក្រោយមកយើងក៏ស្គាល់វាថាជាសារតាំង ឬក៏អារក្ស។



## ការធ្លាក់ចុះរបស់លូសេហ្វឺរ(អារក្សសាតាំង)

*អេសេគាល ២៨:១១-១៧;*
*អេសាយ ១៤:១២-១៥*

ក. ទេវតាគឺជាវិញ្ញាណដែលមានជីវិតដែលព្រះជាម្ចាស់បានបង្កើតមក ដើម្បីឲ្យថ្វាយបង្គំ និងបម្រើព្រះអង្គ។

ខ. មានគ្រូបង្រៀនព្រះគម្ពីរជាច្រើននាក់ជឿជាក់ថាហោរា អេសេគាល និងហោរា អេសាយ បានផ្ដល់ជូននូវការពណ៌នាអំពីការធ្លាក់ចុះរបស់លូសេហ្វឺរ ដោយប្រៀបធៀបលូសេហ្វឺរទៅនឹងស្ដេចនៃទីក្រុងទីរ៉ុស និងទីក្រុងបាប៊ីឡូន។

- សូមអានកណ្ឌគម្ពីរ អេសេគាល ២៨:១១-១៧។ ពីមុន តើលូសេហ្វឺរមានលក្ខណៈយ៉ាងដូចម្ដេច?

- សូមអានកណ្ឌគម្ពីរ អេសាយ ១៤:១២-១៥។ តើលូសេហ្វឺរមានបំណងចិត្តចង់ធ្វើអ្វី ដែលការនោះបាននាំឲ្យវាធ្លាក់ចុះ? ក្នុងខ១៥ តើព្រះជាម្ចាស់បានមានព្រះបន្ទូលថានឹងមានអ្វីកើតឡើងចំពោះវា?

គ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៥:៤១។ តើខគម្ពីរនេះមានភាពស៊ីគ្នាទៅនឹងកណ្ឌគម្ពីរ អេសាយ ១៤:១៥ ដោយរបៀបណា? តម្រុយ៖ «អារក្ស» គឺជាឈ្មោះមួយទៀតរបស់លូសេហ្វឺរ។

ឃ. តើលោកអ្នកគិតថា ទេវតារបស់អារក្សជាអ្នកណា—អស់អ្នកដែលបានលើកឡើងក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២៥:៤១?

ង. យើងមិនដឹងយ៉ាងពិតប្រាកដទេនៅពេលដែលលូសេហ្វឺរបានបះបោរ។ វាទំនងជាបានកើតឡើងមុនហ្នឹងយ៉ាងយូរ ប៉ុន្តែប្រាកដណាស់ វាពិតជាបានកើតឡើងមុនដែលព្រឹត្តិការណ៍ខាងក្រោមនេះបានកើតឡើងទៅទៀត។

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ១៤

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្ដល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្ដែងសេចក្ដីពិត

៥ ក្នុងការបន្តប្រឆាំងទាស់នឹងព្រះជាម្ចាស់ សាតាំងក៏បានល្បួងនាង អេវ៉ា ឲ្យបរិភោគពីដើមឈើដែលព្រះអង្គបានហាម។ ហើយបន្ទាប់មក នាង អេវ៉ា ក៏បានជះឥទ្ធិពលលើលោក អ័ដាម ឲ្យប្រព្រឹត្តដូចនាងដែរ ទោះបើព្រះជាម្ចាស់បានព្រមានយ៉ាងច្បាស់ហើយពេញទៅដោយសេចក្តីស្រឡាញ់ក៏ដោយ។



## ការដែលមនុស្សចាប់ផ្តើមប្រព្រឹត្តអំពើបាប

*លោកុប្បត្តិ ៣:១-៦*

ក. សូមចង់ចាំឃ្លានេះពីកណ្ឌគម្ពីរចុងក្រោយនៃព្រះគម្ពីរ «នាគ គឺពស់ពីចាស់បុរាណដែលជាអារក្ស និងជាសាតាំង» (វិវរណៈ ២០:២)។

ខ. *សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១-៥។* សាតាំងបានលេចទៅកាន់នាង អេវ៉ា ក្នុងរូបរាងជាសត្វពស់ហើយ...

☐ បានលើកសម្រង់សម្តីរបស់ព្រះជាម្ចាស់យ៉ាងមិនត្រឹមត្រូវ ដើម្បីធ្វើឲ្យទ្រង់ហាក់បីដូចជាគ្មានសេចក្តីស្រឡាញ់។ សូមប្រៀបធៀបកណ្ឌគម្ពី លោកុប្បត្តិ ២:១៦-១៧ ជាមួយនឹង ៣:១។

☐ បានបដិសេធថា ព្រះជាម្ចាស់នឹង ហើយក៏មានសមត្ថភាពក្នុងការដាក់ទារុណកម្មចំពោះអស់អ្នកដែលមិនស្តាប់បង្គាប់ទ្រង់ដូចដែលទ្រង់បានសន្យា (*សូមមើល១៤*)

☐ បានលើកជាសំណើថា ព្រះជាម្ចាស់បានប្រទានការព្រមានបែបនេះ ពីព្រោះព្រះអង្គអាត្មានិយម ហើយមានភាពច្រណែន។ (*សូមមើល១៥*)

គ. **ពិត ឬក៏មិនពិត?** *សាតាំងចង់ឲ្យនាង អេវ៉ា មានមន្ទិលសង្ស័យថា ព្រះជាម្ចាស់មិនល្អ មិនស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់ និងមិនបរិសុទ្ធ។*

ឃ. *សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:៦។* តើមានចំណុចបីយ៉ាងអ្វីខ្លះដែលជំរុញឲ្យនាង អេវ៉ា បរិភោគផ្លែឈើដែលព្រះជាម្ចាស់បានហាមប្រាម?

ង. ខណៈពេលដែលយើងសិក្សាព្រះគម្ពីរ វាជាការសំខាន់ណាស់ក្នុងការយល់ថា ទង្វើនៃការមិនស្តាប់បង្គាប់ដោយប្រឆាំងនឹងអ្វីដែលព្រះជាម្ចាស់បានបញ្ជាមិនឲ្យធ្វើគឺហៅថាអំពើបាប។

ទំព័រ ១៥

### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្តា ☐ ព្រះអាទិករ ☐ មានពេញទៅដោយអំណាច ☐ ព្រះដែលការពារមានពេញទៅដោយសេចក្តីមេត្តាករុណា☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្តីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

៦

ដោយសារព្រះជាម្ចាស់ជាព្រះដ៏បរិសុទ្ធនិងជាព្រះដែលថ្កោលទោសដ៏យុត្តិធម៌ នោះលោក អ័ដាម និង អេវ៉ា ក៏ទទួលការវេទនាដែលជាលទ្ធផលនៃការមិនស្ដាប់បង្គាប់របស់ពួកគេ។ ភ្លាមៗនោះពួកគេក៏ស្លាប់ខាងឯព្រលឹងវិញ្ញាណ ហើយមិនយូរមិនឆាប់ក៏ស្លាប់ខាងឯសាច់ឈាមផងដែរ។



## ប្រភពនៃសេចក្ដីស្លាប់

*លោកុប្បត្តិ ៣:៧-១៣;*
*លោកុប្បត្តិ ៥:៥*

ក. ការបែកបាក់គឺជាចំណុចស្នូលនៃសេចក្ដីស្លាប់។ មានសេចក្ដីស្លាប់បីប្រភេទដែលបានកើតឡើងដែលជាលទ្ធផលពីអំពើបាបៈ សេចក្ដីស្លាប់ខាងឯព្រលឹងវិញ្ញាណ សេចក្ដីស្លាប់ខាងឯសាច់ឈាម និងសេចក្ដីស្លាប់ដ៏នៅអស់កល្បជានិច្ច។

ខ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:៧-១៣។ តើមានចំណុចអ្វីខ្លះដែលលោកអ្នកឃើញនៅខាងក្រោមនេះដែលជាលទ្ធផលនៃអំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា?

☐ សេចក្ដីស្លាប់ខាងឯព្រលឹងវិញ្ញាណ (ការបែកចេញពីព្រះជាម្ចាស់) ដែលបណ្ដាលឲ្យការនេះកើតឡើង...

☐ មានការយល់អំពីពិរុទ្ធភាព ភាពអាម៉ាស់ និងភាពភ័យខ្លាចយ៉ាងជ្រាលជ្រៅដែលបណ្ដាលឲ្យ...

☐ បញ្ហាមួយចំនួនក្នុងទំនាក់ទំនងរបស់ពួកគេជាមួយគ្នានិងគ្នា។

គ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៥:៥។ មិនយូរមិនឆាប់ តើលោក អ័ដាម ទទួលបានទណ្ឌកម្មណាផ្សេងទៀតសម្រាប់អំពើបាបរបស់គាត់?

ឃ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៥:៨, ១១, ១៤, ១៧, ២០, ២៧, និង៣១។ បន្ទាប់មកសូមអានកណ្ឌគម្ពីរ រ៉ូម ៥:១២។ តាមរយៈការមិនស្ដាប់បង្គាប់របស់លោក អ័ដាម ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣ មានឥទ្ធិពលពីរយ៉ាងដែលយើងទទួលបានតើវាជាអ្វី?

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ១៦

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្ដល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្ដែងសេចក្ដីពិត

៣ បន្ទាប់មក ព្រះជាម្ចាស់ក៏បានសន្យាថា នឹងមានពូជម្នាក់របស់នាង អេវ៉ា ដែលនឹងយកឈ្នះលើសាតាំងនៅថ្ងៃណាមួយ ដោយសារអំពើអាក្រក់របស់សាតាំងក្នុងការចូលរួមក្នុងអំពើបាបនៃការមិនស្តាប់បង្គាប់របស់លោក អ័ដាម និងនាង អេវ៉ា។



## សេចក្តីសន្យាអំពីអ្នកដែលនឹងយកឈ្នះលើសាតាំង

*លោកុប្បត្តិ ៣:១៤-១៥*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៤។ តើមានតម្រូវការផ្លាស់ប្តូរអ្វីខ្លះដែលព្រះជាម្ចាស់បានដាក់លើសត្វពស់?

ខ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥។ សូមជ្រើសរើសការកាត់ស្រាយមួយ៖

☐ ព្រះជាម្ចាស់គ្រាន់តែបានបង្កើតជម្លោះរវាងមនុស្ស និងសត្វពស់ប៉ុណ្ណោះ។

☐ អត់ទេ! មានចំណុចសំខាន់អ្វីផ្សេងទៀតកំពុងតែកើតឡើងនៅត្រង់នេះ។

គ. ពាក្យ «ពូជ» (កូនចៅ) របស់ស្ត្រីនឹង៖ (សូមគូសចំណាំលើចំណុចទាំងអស់ដែលពិត)

☐ គឺជាមនុស្សប្រុស។

☐ បំផ្លាញផ្នែកដ៏សំខាន់ៗមួយចំនួននៃរាងកាយរបស់សត្វពស់។

☐ ក្នុងដំណើរការនៃការយកឈ្នះលើសត្វពស់ ពូជនោះនឹងរងទុក្ខគ្រោះថ្នាក់លើផ្នែកនៃរាងកាយរបស់គាត់ដែលមិនសូវជាសំខាន់ប៉ុន្មាន។

ឃ. សូមរក្សាចំណុចនេះក្នុងគំនិត៖ បុគ្គលនេះគឺជា «ពូជ» (កូនចៅ) របស់ស្ត្រី—មិនមានការលើកឡើងថាគាត់គឺជាពូជ ឬក៏កូនចៅរបស់មនុស្សប្រុសទេ!



### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្តា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្តីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្តីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 18 16/11/2021 08:57:11 AM

៨

បន្ទាប់ពីលោក អ័ដាម និងនាង អេវ៉ា ព្យាយាមយកស្លឹកល្វាធ្វើជាប៉ឹងបិទបាំងពិរុទ្ធភាព និងភាពអាម៉ាស់របស់ខ្លួន នោះព្រះជាម្ចាស់ក៏បានប្តូរស្លឹកល្វាដោយមានពេញទៅដោយព្រះគុណជាមួយនឹងខោអាវដែលទ្រង់បានធ្វើចេញពីស្បែកសត្វ។



## ការផ្លត់ផ្លង់ការបិទបាំង

*លោកុប្បត្តិ ៣:៧, ២១*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:៧ ហើយបន្ទាប់មក សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៣:២១។

ខ. សូមស្វែងរក យ៉ាងហោចណាស់ ឲ្យបានទូវពីរចំណុចខុសៗគ្នារវាងរបៀបដែលលោក អ័ដាម និងនាង អេវ៉ា ទទួលការស្លៀកពាក់នៅក្នុងខ៧ និងរបៀបដែលពួកគាត់ទទួលការស្លៀកពាក់នៅក្នុងខ២១។ តម្រុយ៖ តើអ្នកណារៀបចំសម្លៀកបំពាក់? តើការបិទបាំងនោះធ្វើពីអ្វី?

គ. *ពិត ឬក៏មិនពិត? យោងតាមអ្វីដែលយើងដឹងថាព្រះជាម្ចាស់បានធ្វើអ្វីសម្រាប់ពួកគាត់ មើលទៅហាក់បីដូចជាថាការដែលលោក អ័ដាម និងនាង អេវ៉ា បាត់បង់ភាពគ្មានទោសគឺជារឿងអចិន្ត្រៃយ៍។*

ឃ. *ពិត ឬក៏មិនពិត? មើលទៅ ហាក់ដូចជាថាអំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា តម្រូវឲ្យមានការសម្លាប់សត្វដែលគ្មានទោសមួយ ឬលើសហ្នឹង ដើម្បីប្រទានការបិទបាំង។*

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ១៨

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

៩ ដោយសារការមិនស្ដាប់បង្គាប់របស់លោក អ័ដាម និងនាង អេវ៉ា បានបណ្ដាលឲ្យពួកគាត់បាត់បង់អភ័យឯកសិទ្ធិរបស់ខ្លួនក្នុងការរស់នៅក្នុងសួនច្បារដ៏មានសុភមង្គលដែលព្រះជាម្ចាស់បានដាក់ពួកគាត់ ដូច្នេះព្រះអង្គក៏បានបណ្ដេញពួកគាត់ចេញពីទីនោះទៅ។



# ការបណ្ដេញចេញពីសួនច្បារអេដែន

*លោកុប្បត្តិ ៣:២២-២៤*

ក. សូមអានប្រយោគដំបូងក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:២២។ **ពិត ឬក៏មិនពិត?** *ដោយសារពួកគាត់បានបរិភោគផ្លែឈើពីដើមដែលព្រះជាម្ចាស់ហាមមិនឲ្យបរិភោគ នោះឥឡូវនេះលោក អ័ដាម និងនាង អេវ៉ា មានចំណេះដឹងនៃអំពើអាក្រក់ចេញពីបទពិសោធន៍ផ្ទាល់ខ្លួន។ បើដូច្នោះមែន តើវាមានភាពខុសគ្នាយ៉ាងដូចម្ដេចពីចំណេះដឹងរបស់ព្រះជាម្ចាស់អំពីអំពើអាក្រក់?*

ខ. សូមអានផ្នែកទីពីរនៃខ២២ ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣ រហូតដល់ ៣:២៤។

- សេចក្ដីពិតទី១៖ ខ២៣-២៤ប្រាប់យើងថា ព្រះជាម្ចាស់បានបណ្ដេញលោក អ័ដាម និងនាង អេវ៉ា ចេញពីសួនច្បារអេដែន។
- សេចក្ដីពិតទី២៖ ផ្នែកទីពីរនៃខ២២បើកបង្ហាញអំពីមូលហេតុរបស់ព្រះជាម្ចាស់ក្នុងការបណ្ដេញពួកគាត់ចេញ។

គ. សំណួរទាក់ទងនឹងការបណ្ដេញចេញរបស់លោក អ័ដាម និងនាង អេវ៉ា ពីសួនច្បារអេដែន៖

- តើនេះជាព្រឹត្តិការណ៍នៃការថ្កោលទោសរបស់ព្រះជាម្ចាស់មែនឬ? សូមពន្យល់។

- ក្នុងរបៀបមួយចំនួន តើនេះគឺជាព្រឹត្តិការណ៍ដែលមានពេញទៅដោយព្រះគុណរបស់ព្រះជាម្ចាស់មែនឬ? សូមពន្យល់។

## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

ទំព័រ ១៩

☐ ព្រះដ៏មានគ្រប់ព្រះចេស្ដា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្ដីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្ដីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

១០ ជាច្រើនឆ្នាំបន្តទៀត មនុស្សលោកកាន់តែប្រព្រឹត្តអំពើបាបបន្ថែមទៀត រហូតដល់ព្រះជាម្ចាស់បំផ្លាញផែនដី និងរាល់អ្វីៗដែលនៅលើផែនដីនេះចោលតាមរយៈទឹកជំនន់ដ៏ធំមួយ លើកលែងតែលោកណូអេ ដែលគាត់ជាអ្នកកោតខ្លាចព្រះជាម្ចាស់ និងគ្រួសាររបស់គាត់។



# ទឹកជំនន់ដ៏ធំ

*លោកុប្បត្តិ ៦:៥-៨:២២*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៦:៥-៧, ១១-១២។ តើអ្វីទៅដែលបណ្តាលឲ្យព្រះជាម្ចាស់ធ្វើឲ្យមានទឹកជំនន់ដ៏ឃោរឃៅកើតឡើង? តើបញ្ហានេះមានភាពធ្ងន់ធ្ងរខ្លាំងប៉ុណ្ណាដែលបណ្តាលឲ្យទឹកជំនន់កើតឡើង?

ខ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៦:៨-១០ និង៧:១។ តើលោក ណូអេ មានលក្ខណៈខុសគ្នាពីអ្នកដទៃនៅជំនាន់គាត់ដោយរបៀបណាខ្លះ? តើលោកអ្នកគិតថាឃ្លា «[លោក ណូអេ] ក៏ដើរជាមួយនឹងព្រះ» មានន័យយ៉ាងដូចម្តេច?

គ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៦:៥-៨:២២។ ប្រសិនបើយើងកាត់ស្រាយដំណើររឿងនេះឲ្យចំៗ តើវាអាចទេដែលថាទឹកជំនន់៖

- ☐ ជាទឹកជំនន់ដែលកើតឡើងតាមតំបន់?
- ☐ ជាទឹកជំនន់ដែលកើតឡើងពាសពេញពិភពលោកទាំងមូល?

ឃ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ៦:១៥។ តើទូកនោះធំប៉ុណ្ណា?

ង. ចេញពីសាច់រឿងនេះ តើយើងរៀនបានអ្វីខ្លះអំពី៖

- មនុស្ស?
- ព្រះជាម្ចាស់?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ២០

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

១១ ប្រមាណជាច្រើនឆ្នាំក្រោយទឹកជំនន់ ព្រះជាម្ចាស់បានត្រាស់ហៅលោក អ័ប្រាហាំ ឲ្យធ្វើជាបិតានៃជាតិសាសន៍ដ៏ធំមួយ ដែលតាមរយៈគាត់មនុស្សជាច្រើនលើផែនដីនេះនឹងទទួលបានព្រះពរខាងឯវិញ្ញាណដ៏ពិសេស។



## សេចក្តីសន្យាទៅកាន់លោក អ័ប្រាហាំ

*លោកុប្បត្តិ ១១:៣១-១២:៧*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១១:៣១-៣២ ហើយស្វែងរកទីក្រុងអ៊ើរ ហារ៉ាន និងកាណានក្នុងផែនទីលើទំព័រ៨ និង៩។

ខ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១២:១-៣។ នៅក្នុងចុង១៣ មានសេចក្តីសន្យាដ៏ពិសេសមួយដែលយើងគួរចងចាំ។ ដោយសារសេចក្តីសន្យាដែលថា គ្រប់គ្រួសារលើផែនដីនឹងទទួលបានព្រះពរតាមរយៈលោក អ័ប្រាហាំ ត្រូវបានលើកឡើងម្តង ហើយម្តងទៀតនៅក្នុងព្រះគម្ពីរ ដូច្នេះនេះពិតជាសំខាន់ណាស់។ តើក្នុងអត្ថន័យអ្វីដែលថាសេចក្តីសន្យានេះអាចកើតឡើងបាន? ដើម្បីឲ្យស្គាល់ចម្លើយលើសំណួរនេះបាន លោកអ្នកត្រូវតែរង់ចាំ ហើយមើលអំពីរបៀបដែលដំណើររឿងនៃសេចក្តីសង្ឃឹមនៃព្រះគម្ពីរនឹងបន្តកើតឡើងបន្ថែមទៀត។

គ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១២:៤-៧។ តើព្រះជាម្ចាស់បានបន្ថែមសេចក្តីសន្យាអ្វីទៅកាន់លោក អ័ប្រាហាំ ក្នុង១៧?

### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

ទំព័រ ២១

☐ ព្រះដ៏មានគ្រប់ព្រះចេស្តា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្តីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្តីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

១២ ព្រះជាម្ចាស់បានល្បងលជំនឿរបស់លោក អ័ប្រាហាំ ដោយព្រះអង្គបានស្នើឲ្យគាត់បូជាលោក អ៊ីសាក ដែលជាកូនរបស់គាត់ដែលតាមរយៈកូនម្នាក់នេះ នោះព្រះពរខាងឯព្រលឹងវិញ្ញាណនឹងកើតមានឡើងប៉ុន្តែនៅគ្រាចុងក្រោយ ព្រះជាម្ចាស់បានផ្តត់ផ្គង់យញ្ញបូជាជំនួសទៅវិញ។



# ការបូជាលោក អ៊ីសាក

*លោកុប្បត្តិ ២២:១-១៨*

ក. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២២:១-១៤។ តើលោកអ្នកគិតថា ហេតុអ្វីបានជា...

- ព្រះជាម្ចាស់បានស្នើឲ្យលោក អ័ប្រាហាំ ថ្វាយកូនគាត់ជាយញ្ញបូជា?
- លោក អ័ប្រាហាំ ត្រាប់តាមបញ្ញាដ៏ប្លែកមួយនេះ?

ខ. ចម្លើយគឺទាក់ទងទៅនឹងអ្វីដែលលោក អ័ប្រាហាំ បានជឿថាព្រះជាម្ចាស់អាច ហើយនឹងធ្វើសម្រាប់គាត់។

- សូមអានខ៥ជាថ្មីម្តងទៀត។ ហើយបន្ទាប់មក សូមអានកណ្ឌគម្ពីរ ហេព្រើរ ១១:១៧-១៩។ តើលោក អ័ប្រាហាំ បានជឿថាព្រះជាម្ចាស់អាចធ្វើអ្វីបាន?
- សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២២:៧-១៤ ជាថ្មីម្តងទៀត។ ក្នុងករណីនេះ តើជំនឿរបស់លោក អ័ប្រាហាំ បានទទួលជាអំណះអំណាងដោយរបៀបណា?

គ. សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ២២:១៥-១៨។ តើលោកអ្នកឃើញសេចក្ដីសន្យាអ្វីក្នុងខ១៨? តើមានចំណុចខុសគ្នាបន្តិចបន្តួចយ៉ាងដូចម្តេចនៅក្នុងត្រង់នេះពេលប្រៀបធៀបជាមួយនឹងកណ្ឌគម្ពីរ លោកុប្បត្តិ ១២:៣? តម្រុយៈ សូមប្រៀបធៀប «ដោយសារអ្នក» ជាមួយនឹង «ពូជពង្សរបស់អ្នក»។

ឃ. ក្រោយមកលោក អ៊ីសាក មានកូនម្នាក់ដែលគាត់បានដាក់ឈ្មោះថា យ៉ាកុប (ដែលព្រះជាម្ចាស់បានប្តូរឈ្មោះសាជាថ្មីថា *អ៊ីស្រាអែល*) ដែលមានកូនប្រុស ១២ នាក់។ ខណៈពេលដែលលោក អ៊ីស្រាអែល ត្រៀមខ្លួនក្នុងការស្លាប់ តើគាត់បានសន្យាអ្វីទៅកាន់លោក យូដា ដែលជាកូនប្រុសរបស់គាត់ក្នុងពាក្យពីរបីដំបូងនៃកណ្ឌគម្ពីរ លោកុប្បត្តិ ៤៩:១០? តម្រុយៈ ពាក្យ «ដំបងរាជ្យ» គឺជាឈើច្រត់មួយដែលស្តេចកាន់ជាតំណាងឲ្យអំណាចនៃខ្សែស្តេច។

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ២២

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

១៣ បន្ទាប់ពីកូនចៅមួយចំនួនរបស់លោក អ័ប្រាហាំ (សាសន៍អ៊ីស្រាអែល) បានក្លាយជាទាសករនៅប្រទេសអេស៊ីព្ទ នោះព្រះជាម្ចាស់ក៏បានត្រាស់ហៅលោក ម៉ូសេ ឲ្យដឹកនាំពួកគេចេញពីប្រទេសអេស៊ីព្ទ ចូលទៅកាន់ស្រុកកាណាន ដែលជាទឹកដីដែលព្រះជាម្ចាស់បានសន្យាពីមុនទៅកាន់លោក អ័ប្រាហាំ។



## ការត្រាស់ហៅលោក ម៉ូសេ ឲ្យធ្វើជាអ្នកដឹកនាំ

*និក្ខមនំ ១:១-១៤; និក្ខមនំ ៣:១-១៧*

ក. ព្រះជាម្ចាស់បានតម្រង់កាលៈទេសៈមួយចំនួនក្នុងគ្រួសាររបស់លោក អ៊ីស្រាអែល ក្នុងការដាក់លោក យ៉ូសែប ដែលជាកូនប្រុសរបស់គាត់ក្នុងប្រទេសអេស៊ីព្ទឲ្យធ្វើជាអ្នកដឹកនាំដ៏ធំម្នាក់ ដើម្បីរៀបចំផ្លូវសម្រាប់គ្រួសារលោក អ៊ីស្រាអែល ដែលនឹងទៅ។

ខ. សូមអានកណ្ឌគម្ពីរ និក្ខមនំ ១:១-៧។ តើខ៧បានពណ៌នាយ៉ាងដូចម្ដេចអំពីការដែលសាសន៍អ៊ីស្រាអែលបានចម្រើនឡើង?

គ. សូមអានកណ្ឌគម្ពីរ និក្ខមនំ ១:៨-១៤។ តើមានអ្វីបានកើតឡើងបន្ទាប់ពីផារ៉ោន (ស្ដេច) ថ្មីនៃប្រទេសអេស៊ីព្ទបានឡើងកាន់អំណាច—អង្គដែលមិនចង់ចាំលោក យ៉ូសែប ដែលជាកូនរបស់លោក អ៊ីស្រាអែល ឬក៏សេចក្ដីសន្យារបស់ផារ៉ោនពីមុនៗទៅកាន់លោក អ៊ីស្រាអែល?

ឃ. សូមអានកណ្ឌគម្ពីរ និក្ខមនំ ៣:១-១០។ តើព្រះជាម្ចាស់មានការផែនអ្វីក្នុងព្រះចិន្តារបស់ទ្រង់សម្រាប់លោក ម៉ូសេ? តើព្រះជាម្ចាស់បានអះអាងថា ព្រះអង្គមានទំនាក់ទំនងពិសេសអ្វីចំពោះសាសន៍អ៊ីស្រាអែល?

ង. សូមអានកណ្ឌគម្ពីរ និក្ខមនំ ៣:១១-១៧។ តើលោក ម៉ូសេ ត្រូវប្រាប់សាសន៍អ៊ីស្រាអែលយ៉ាងដូចម្ដេចនៅពេលដែលពួកគេសួរគាត់ថា «តើព្រះអង្គមានព្រះនាមអ្វី?»។

- ពីការណែនាំរបស់ព្រះជាម្ចាស់ក្នុងខ១៤?
- ពីការណែនាំរបស់ព្រះជាម្ចាស់ក្នុងខ១៥?

ទំព័រ ២៣

### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្ដា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្ដីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្ដីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

១៤ ដើម្បីរំដោះសាសន៍អ៊ីស្រាអែលចេញ ព្រះជាម្ចាស់បានចាត់គ្រោះកាចមួយចំនួនទៅកាន់ប្រទេសអេស៊ីព្ទ ដែលមានរួមទាំងការស្លាប់នៃកូនច្បងក្នុងគ្រប់គ្រួសារទាំងអស់ ប៉ុន្តែព្រះជាម្ចាស់ការពារអស់អ្នកដែលបង្ហាញជំនឿយ៉ាងត្រឹមត្រូវក្នុងព្រះអង្គ។



# គ្រោះកាច និងបុណ្យរំលង

*និក្ខមនំ ១២:១-១៣, ២១-២៣*

ក. ដើម្បីបង្ហាញអំណាចរបស់ព្រះអង្គលើព្រះក្លែងក្លាយនៃប្រទេសអេស៊ីព្ទ និងដើម្បីបញ្ចុះបញ្ចូលផារ៉ោនឲ្យដោះលែងសាសន៍អ៊ីស្រាអែល នោះព្រះជាម្ចាស់ក៏បានចាត់គ្រោះកាចដ៏គួរឲ្យកាចសាហាវមួយចំនួនលើប្រទេសអេស៊ីព្ទ។គ្រោះកាចដំបូងក្នុងចំណោមគ្រោះកាចៗទាំងនោះគឺការស្លាប់នៃកូនច្បង និងសត្វនានា។

១. សូមអានកណ្ឌគម្ពីរ និក្ខមនំ ១២:១-១៣, ២១-២៣។

- តើព្រះអង្គតម្រូវឲ្យមានសត្វដែលមានលក្ខណៈយ៉ាងដូចម្តេចក្នុងការថ្វាយជាយញ្ញបូជា? *(សូមមើលខ៥)*

- តើសាសន៍អ៊ីស្រាអែលត្រូវធ្វើអ្វីជាមួយនឹងឈាមរបស់សត្វនេះ? *(សូមមើលខ៧ និង២២)*

- តើមានសញ្ញាសម្គាល់អ្វីដែលនឹងបណ្តាលឲ្យព្រះជាម្ចាស់រំលងផ្ទះដោយមិនប្រតិបត្តិគ្រោះកាចនៃការស្លាប់ *(សូមមើលខ១២-១៣, ២៣)*

- ព្រះជាម្ចាស់បានបង្កើតខួបរម្លឹកមួយ ដើម្បីរម្លឹកសាសន៍អ៊ីស្រាអែលអំពីការរំដោះនេះចេញពីការស្លាប់។ តើគេហៅខួបរម្លឹកនេះជាអ្វី? *(សូមមើលខ២៧)*

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ២៤

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

១៥ បន្ទាប់មកលោក ម៉ូសេ ក៏បាននាំសាសន៍អ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទនៅពេលដែលព្រះជាម្ចាស់ញែកទឹកនៃសមុទ្រក្រហម ដោយរៀបចំផ្លូវសម្រាប់ពួកគេតម្រង់ទៅទឹកដីសន្យានៃស្រុកកាណាន។



## ការដែលសាសន៍អ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទ

*និក្ខមនំ ១៤:១-៣១*

ក. សូមអានកណ្ឌគម្ពីរ និក្ខមនំ ១៤:១-១២។ តើអ្វីទៅបណ្ដាលឲ្យមានភាពក្លាហាន (ក្នុង៦៨) របស់សាសន៍អ៊ីស្រាអែលប្រែរទៅជាភាពភ័យខ្លាចយ៉ាងឆាប់រហ័ស (ក្នុង៦១០)?

ខ. យោងតាម ៦១-២ & ៩ ក្នុងកណ្ឌគម្ពីរ និក្ខមនំ ១៤ តើអ្វីទៅជាឈ្មោះនៃទីកន្លែងដែលសាសន៍អ៊ីស្រាអែលបានបោះតង់? សូមស្វែងរកទីកន្លែងបម្រុងនោះលើផែនទីក្នុងទំព័រ៨។

គ. សូមអានកណ្ឌគម្ពីរ និក្ខមនំ ១៤:១៣-១៤។ តើយើងឃើញការបង្ហាញជំនឿលើព្រះជាម្ចាស់ក្នុងពាក្យពេចន៍របស់លោក ម៉ូសេ ដោយរបៀបណា?

ឃ. ខណៈពេលដែលលោកអ្នកបន្តអានអ្វីដែលនៅសល់ក្នុងជំពូកនេះ សូមស្វែងរកយ៉ាងហោចណាស់ឲ្យបាន៣ចំណុចធំៗនៃទង្វើនៃការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើ ដើម្បីនាំឲ្យសាសន៍អ៊ីស្រាអែលអាចគេចផុតចេញពីពួកសាសន៍អេស៊ីព្ទក្នុងការចាកចេញពីប្រទេសអេស៊ីព្ទ។ សូមអានកណ្ឌគម្ពីរ និក្ខមនំ ១៤:១៥-៣១។ សូមកត់សម្គាល់លើ និងពិភាក្សាអំពីការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើឡើង។

### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

ទំព័រ ២៥

- ☐ ព្រះដ៏មានគ្រប់ព្រះចេស្ដា
- ☐ ព្រះអាទិករ
- ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌
- ☐ ព្រះដែលការពារមានពេញទៅដោយសេចក្ដីមេត្តាករុណា
- ☐ ព្រះដ៏បរិសុទ្ធ
- ☐ ព្រះដែលរក្សាសេចក្ដីសន្យាយ៉ាងស្មោះត្រង់
- ☐ ព្រះដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច

១៦

ក្នុងទីរហោស្ថានរវាងប្រទេសអេស៊ីព្ទនិងស្រុកកាណាន ព្រះជាម្ចាស់ដ៏ជាព្រះដែលបរិសុទ្ធល្អឥតខ្ចោះបានប្រទានទៅកាន់សាសន៍អ៊ីស្រាអែលនូវក្រឹត្យវិន័យមួយចំនួនដែលបង្ហាញអំពីអ្វីដែលព្រះអង្គស្អប់ដែលយើងហៅថាអំពើបាប។



# ក្រឹត្យវិន័យ១០ប្រការ

*និក្ខមនំ ២០:១-១៧*

ក. ព្រះជាម្ចាស់បានប្រទានរបនាសម្ព័ន្ធនៃក្រឹត្យវិន័យជាច្រើនទៅកាន់សាសន៍អ៊ីស្រាអែល ប៉ុន្តែចំណុចស្នូលនៃរបនាសម្ព័ន្ធច្បាប់គឺមាន ជាទូទៅ ក្នុងអ្វីដែលគេហៅថាក្រឹត្យវិន័យ១០ប្រការ។ សូមអានកណ្ឌគម្ពីរ និក្ខមនំ ២០:១-១៧ ហើយកត់សម្គាល់លើមូលដ្ឋានគ្រឹះទាំង១០លើក្រឹត្យវិន័យទាំងនោះ។

ខ. តើក្រឹត្យវិន័យទាំងនោះបើកបង្ហាញអំពីចរិក និងលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេចខ្លះ?

គ. ក្នុងប្រពៃណីរបស់លោកអ្នក ក្នុងចំណោមក្រឹត្យវិន័យទាំងនេះ ជាទូទៅ តើគេប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យមួយណាខ្លាំងជាងគេ?

ឃ. តើក្រឹត្យវិន័យទាំងនេះបើកបង្ហាញអំពីចរិក និងលក្ខណសម្បត្តិរបស់មនុស្សយ៉ាងដូចម្ដេចខ្លះ?

ង. ដើម្បីឲ្យបុគ្គលណាម្នាក់មានពិរុទ្ធភាពក្នុងការធ្វើខុស—ការមានបាប តើគាត់ត្រូវប្រព្រឹត្តល្មើសលើក្រឹត្យវិន័យប៉ុន្មានរបស់ព្រះជាម្ចាស់? *(សូមមើលព្រឹត្តិការណ៍ទី៥ក្នុងទំព័រ១៦)*

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ២៦

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្ដល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្ដែងសេចក្ដីពិត

១៧ បន្ទាប់មក ព្រះជាម្ចាស់បានណែនាំលោកម៉ូសេ ឲ្យសាងសង់ទីកន្លែងសម្រាប់ថ្វាយបង្គំដែលអាចបំផ្លាស់ទីបាន ដែលសាសន៍អ៊ីស្រាអែលអាចទៅថ្វាយយញ្ញបូជា ហើយទទួលបានការអត់ទោសពីអំពើបាបរបស់ខ្លួន។



## រោងឧបោសថនៅទីរហោស្ថាន

*និក្ខមនំ ៤០:១៧-៣៤;*
*លេវីវិន័យ ១:១-៤, ១០*

*ចំណុចសម្គាល់៖ ប្រសិនបើនេះជាការដឹកនាំការសិក្សាដោយមានអ្នកដែលនាំ នោះអ្នកដឹកនាំគួរត្រៀមខ្លួនជាស្រេចក្នុងការពន្យល់អំពីតួនាទី និងគោលបំណងនៃផ្នែកចម្បងៗនៃរោងឧបោសថ។ សូមទៅទាញយកឯកសារនៃការណែនាំសម្រាប់អ្នកដឹកនាំពីគេហទំព័រគាំទ្រសម្រាប់ព័ត៌មានបន្ថែម។*

ក. សូមអានកណ្ឌគម្ពីរ និក្ខមនំ ៤០:១៧-៣៤។ សូមប្រៀបធៀបនូវអ្វីដែលលោកអ្នកអាននៅត្រង់នេះជាមួយនឹងរោងឧបោសថក្នុងទំព័រ១០។

ខ. រោងឧបោសថគឺជាកន្លែងសម្រាប់ថ្វាយបង្គំ ប៉ុន្តែក៏ជាកន្លែងដែលអំពើបាបរបស់បុគ្គលណាម្នាក់អាចទទួលបានការលោះបាបបាន (ការបាំង ឬការអត់ទោស)ផងដែរ តាមរយៈការថ្វាយយញ្ញបូជាដូចជាពីហ្វូងសត្វចិញ្ចឹមនៃសត្វពាហនៈ និងសត្វពពែ ហ្វូងសត្វចៀម ឬក៏សត្វស្លាប។ សត្វនៃយញ្ញបូជានោះនឹងស្លាប់ក្នុងលក្ខណៈជាការលោះបាបជំនួសអំពើបាបរបស់បុគ្គលម្នាក់នោះ។ សូមអានកណ្ឌគម្ពីរ លេវីវិន័យ ១:១-៤ និង១០-១៤។ សូមរៀបរាប់បែបជាសង្ខេបអំពីទម្រង់ការដែលកើតឡើងជាបន្តបន្ទាប់។

គ. តើលោកអ្នកឃើញថាមានចំណុចស្រដៀងគ្នាអ្វីខ្លះរវាងអ្វីដែលកើតឡើងនៅទីនេះ និងអ្វីដែលកើតឡើងក្នុងព្រឹត្តិការណ៍ទី៨ក្នុងទំព័រ១៩ និងព្រឹត្តិការណ៍ទី១៤ក្នុងទំព័រ២៥?



### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

☐ ព្រះដ៏មានគ្រប់ព្រះចេស្ដា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្ដីមេត្តាករុណា
☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្ដីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 28 16/11/2021 08:57:15 AM

១៨ នៅតាមផ្លូវទៅស្រុកកាណាន សាសន៍អ៊ីស្រាអែលបានបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ហើយព្រះអង្គក៏បានដាក់ទោសពួកគេតាមរយៈការដែលពស់ចឹកយ៉ាងកាចសាហាវ ប៉ុន្តែព្រះជាម្ចាស់បានផ្តត់ផ្គង់នូវថ្នាំព្យាបាលដែលមានពេញទៅដោយព្រះគុណសម្រាប់ទុក្ខលំបាករបស់ពួកគេ។



# ពស់លង្ហិន

*ជនគណនា ២១:៤-៩*

ក. សូមអានកណ្ឌគម្ពីរ ជនគណនា ២១:៤-៩ ហើយកត់សម្គាល់លើផ្នែកនីមួយៗនៃសាច់រឿងដែលកើតឡើង៖

- អំពើបាបនៃការមិនជឿ និងការបះបោរ
- ការថ្កោលទោស
- ការលន់តួ
- ការអធិស្ឋានសម្រាប់ការរំដោះ
- ការផ្គត់ផ្គង់របស់ព្រះជាម្ចាស់
- ជំនឿ
- ជីវិត

ខ. តើសាសន៍អ៊ីស្រាអែលត្រូវធ្វើអ្វី ដើម្បីឲ្យទទួលបានការរួចពីស្លាប់?

គ. សូមចងចាំព្រឹត្តិការណ៍នេះ ពីព្រោះក្រោយមកទៀតក្នុងការបន្តបើកបង្ហាញសាច់រឿងនៃព្រះគម្ពីរ នោះនឹងមានគ្រូដ៏សំខាន់ម្នាក់ដែលនឹងលើកឡើងម្តងទៀតអំពីសាច់រឿងនេះ ហើយពន្យល់នូវចំណុចសំខាន់ទាក់ទងនឹងទំនាយនៃព្រឹត្តិការណ៍នេះ។

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ២៨

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

១៩ បន្ទាប់ពីសាសន៍អ៊ីស្រាអែលបានចូលស្រុកកាណាន ព្រះជាម្ចាស់បានសោយរាជ្យលើពួកគេតាមរយៈពួកចៅហ្វាយ និងស្តេចនានាដែលមានរួមទាំងស្តេច ដាវីឌ ដែលព្រះជាម្ចាស់បានសន្យាថានគររបស់ទ្រង់នឹងនៅយ៉ាងអស់កល្បជានិច្ចតាមរយៈពូជពង្សដ៏ពិសេសមួយ។



# ការសោយរាជ្យរបស់ស្តេច ដាវីឌ

*២សាំយូអែល ៧:១-១៦*

ក. ពួកចៅហ្វាយមួយចំនួនបានសោយរាជ្យលើសាសន៍អ៊ីស្រាអែលក្នុងស្រុកកាណាន ហើយបន្ទាប់មកតាមរយៈស្តេចមួយចំនួនទៀត។ ដាវីឌ ដែលជាស្តេចទី២ គឺជាបុគ្គលដ៏អស្ចារ្យបំផុត ហើយមានពេញទៅដោយការកោតខ្លាចព្រះជាម្ចាស់ខ្លាំងជាងគេបង្អស់ក្នុងចំណោមពួកគេទាំងអស់។ សូមអានកណ្ឌគម្ពីរ ២សាំយូអែល ៧:១-៧។ តើស្តេច ដាវីឌ ចង់ស្អាង «វិហារ» បែបម៉េចសម្រាប់ព្រះជាម្ចាស់? ចំណុចសម្គាល់៖ ស្តេច ដាវីឌ បានប្រមូលសម្ភារៈជាច្រើន ហើយក៏បានរៀបចំផែនការក្នុងការសង់វិហារដ៏អស្ចារ្យក្នុងទីក្រុងយេរូសាឡឹម ដែលក្រោយមកទៀតស្តេច សាឡូម៉ូន ដែលជាបុត្រារបស់ទ្រង់បានសាងសង់បង្ហើយ។

ខ. សូមចងចាំផងដែរថា ពេលខ្លះពាក្យ «ផ្ទះ/វិហារ/សំណាក់» ក៏សំដៅទៅលើពូជពង្សកូនចៅនៃបុគ្គលណាម្នាក់ផងដែរ។ សូមអានផ្នែកចុងក្រោយនៃកណ្ឌគម្ពីរ ២សាំយូអែល ៧:១១ រហូតដល់ខ១៣។ តើព្រះជាម្ចាស់បានសន្យាថាព្រះអង្គនឹងសង់ «ផ្ទះ/វិហារ/សំណាក់» យ៉ាងដូចម្តេចសម្រាប់ស្តេច ដាវីឌ?

គ. សូមអានកណ្ឌគម្ពីរ ២សាំយូអែល ៧:១៦។ តើមានចំណុចសម្គាល់អ្វីដែលយើងឃើញថា សេចក្តីសន្យាទាក់ទងនឹង «ផ្ទះ/វិហារ/សំណាក់នេះ» មានសុពលភាពលើសពីការសោយរាជ្យរបស់ស្តេច សាឡូម៉ូន ដែលជាបុត្រារបស់ទ្រង់?

ឃ. សូមទាយទៅមើលថាតើ ដាវីឌ មកពីកុលសម្ព័ន្ធនៃសាសន៍អ៊ីស្រាអែលមួយណា? តម្រុយ៖ សូមចងចាំអំពីសេចក្តីសន្យារបស់លោក អ៊ីស្រាអែល ទៅកាន់លោក យូដា ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៤៩:១០។ សូមមើលព្រឹត្តិការណ៍ទី១២ក្នុងទំព័រ២៣។

## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះជាម្ចាស់

ទំព័រ ២៩

☐ ព្រះដ៏មានគ្រប់ព្រះចេស្តា ☐ ព្រះអាទិករ ☐ ព្រះដែលថ្កោលទោសដ៏យុត្តិធម៌ ☐ ព្រះដែលការពារមានពេញទៅដោយសេចក្តីមេត្តាករុណា ☐ ព្រះដ៏បរិសុទ្ធ ☐ ព្រះដែលរក្សាសេចក្តីសន្យាយ៉ាងស្មោះត្រង់ ☐ ព្រះដែលមានព្រះជន្មដ៏នៅអស់កល្បជានិច្ច

២០ ពាសពេញប្រវត្តិសាស្ត្រអ៊ីស្រាអែលព្រះជាម្ចាស់បានបណ្តាលឲ្យហោរានានារបស់ព្រះអង្គរៀបរាប់ជាមុនអំពីព័ត៌មានលម្អិតជាច្រើនទាក់ទងទៅនឹងបុគ្គលដ៏ពិសេស ម្នាក់នៃសាសន៍អ៊ីស្រាអែល គឺស្តេច និងព្រះអង្គសង្គ្រោះដែលនឹងប្រសូតនាពេលអនាគត។



## ទំនាយអំពីព្រះមេស្ស៊ីដែលនឹងយាងមក

*អេសាយ ៧:៤;៩:១-២, ៦-៧; ៥២:១៣-៥៣:១២*

ក. **ការប្រសូតរបស់ទ្រង់គឺ៖** សូមអានកណ្ឌគម្ពីរ អេសាយ ៧:១៤។ សូមនឹកចាំអំពីសេចក្តីសន្យាទាក់ទងទៅនឹងអ្នកយកឈ្នះលើសាតាំង ដែលត្រូវបានលើកឡើងថាគឺជាពូជរបស់ស្ត្រី ប៉ុន្តែមិនមានការលើកឡើងរៀបរាប់ប្រាប់អំពីឪពុកនោះទេ។ សូមមើលព្រឹត្តិការណ៍ទី៧ក្នុងទំព័រ១៨។ តើលោកអ្នកអាចឃើញការភ្ជាប់គ្នារវាងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥ & កណ្ឌគម្ពីរ អេសាយ ៧:១៤ ដោយរបៀបណាខ្លះ?

ខ. **កន្លែងប្រសូតរបស់ទ្រង់៖** សូមអានកណ្ឌគម្ពីរ  មីកា ៥:២។ តើខគម្ពីរនេះមានភាពស៊ីគ្នាជាមួយនឹង «ដំបងរាជ្យ» ដែលសន្យាឡើងក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៤៩:១០ ដោយរបៀបណា? សូមមើលព្រឹត្តិការណ៍ទី១២ក្នុងទំព័រ២៣។

គ. **ព័ន្ធកិច្ចរបស់ទ្រង់ក្នុងស្រុកកាលីឡេ៖** សូមអានកណ្ឌគម្ពីរ អេសាយ ៩:១-២ & ៦។ សូមសម្គាល់ថាតំបន់នេះគឺជិតសមុទ្រកាលីឡេ។

ឃ. **ការសុគតរបស់ទ្រង់៖** សូមអានកណ្ឌគម្ពីរ អេសាយ ៥២:១៣-៥៣:១២។ តើនឹងមានការប្រព្រឹត្តិអាក្រក់ៗបែបណាខ្លះកើតឡើងចំពោះបុរសនេះ ដែលមាននៅក្នុងការពណ៌នានេះ ហើយជាលទ្ធផលតើនឹងមានចំណុចល្អៗអ្វីខ្លះដែលកើតចេញពីការរងទុក្ខរបស់គាត់?

ង. **ការមានព្រះជន្មរស់ឡើងវិញពីការសុគតរបស់ទ្រង់៖** សូមអានកណ្ឌគម្ពីរ ទំនុកតម្កើង ១៦:៨-១០។ តើខ១០បង្ហាញអំពីអ្វីខ្លះ?

ច. **នគរដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់៖** សូមអានកណ្ឌគម្ពីរ អេសាយ ៩:៦-៧។

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៣០

☐ វិញ្ញាណដែលមានវត្តមានគ្រប់ទីកន្លែង ☐ ព្រះដែលសព្វញ្ញូតភាព ☐ ព្រះដែលមានទំនាក់ទំនង ☐ ព្រះវរបិតាដែលស្រឡាញ់
☐ ព្រះដែលផ្តល់ក្រឹត្យវិន័យដែលមានពេញទៅដោយអំណាច ☐ ព្រះប្រោសលោះដែលមានពេញទៅដោយការអត់ទោស ☐ ព្រះដែលសម្តែងសេចក្តីពិត

២១ ក្នុងពេលវេលាគ្រោងទុករបស់ព្រះជាម្ចាស់ ព្រះអង្គបានចាត់ព្រះរាជបុត្រារបស់ទ្រង់មកកាន់ផែនដី ឲ្យប្រសូតពីនាងក្រមុំព្រហ្មចារីដែលមានឈ្មោះថានាង ម៉ារា ក្នុងនាមជាស្តេច និងព្រះអង្គសង្គ្រោះដ៏ពិសេសដែលព្រះអង្គបានសន្យាអស់ជាច្រើនសតវត្សរ៍មក។



## ការប្រសូតរបស់ព្រះយេស៊ូវនៅភូមិណាសារ៉ែត

*ម៉ាថាយ ១:១-២, ១៨-២៥;*
*លូកា ២:១-១៤*

ក. សូមអានចំណុចដំបូងនៃបញ្ជីពង្សាវតារក្សត្ររបស់ព្រះយេស៊ូវក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១:១-២។ តើមានចំណុចពិសេសៗអ្វីដែលលោកអ្នកចង់ចាំអំពីបុព្វបុរសរបស់ព្រះយេស៊ូវ?

ខ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ១:១៨-២៥។ តើមានចំណុចសំខាន់អ្វីខ្លះដែលយើងឃើញនៅត្រង់នេះដែលថាព្រះយេស៊ូវគឺជាកូនដ៏ពិសេស? តម្រុយ៖ របៀបដែលព្រះអង្គបានយាងមកយកកំណើត និងព្រះនាម «យេស៊ូវ និង «អេម៉ាញូអែល» របស់ទ្រង់?

គ. សូមអានកណ្ឌគម្ពីរ លូកា ២:១-៧ ហើយប្រៀបធៀបជាមួយនិងទំនាយក្នុងកណ្ឌគម្ពីរ មីកា ៥:២។ សូមមើលព្រឹត្តិការណ៍ទី២០ក្នុងទំព័រ៣០។

ឃ. សូមអានកណ្ឌគម្ពីរ លូកា ២:៨-១៤។ មានការពណ៌នាអំពីព្រះយេស៊ូវថា «ព្រះសង្គ្រោះមួយអង្គ...គឺព្រះគ្រីស្ទជាព្រះអម្ចាស់»។ តើពាក្យ «ព្រះសង្គ្រោះ» «ព្រះគ្រីស្ទ» និង «ព្រះអម្ចាស់» បង្ហាញអំពីអ្វីខ្លះ? តម្រុយ៖ ពាក្យ «ព្រះគ្រីស្ទ» គឺជាពាក្យក្នុងភាសាក្រិកដែលមានភាពស្មើគ្នាទៅនឹងពាក្យ «*ព្រះមេស៊ី*» ក្នុងភាសាហេប្រឺ (ដែលមានន័យថាជាបុគ្គលម្នាក់ដែលទទួលបានការចាក់ប្រេងតាំងឲ្យធ្វើជាស្តេច)។

ង. នៅក្រោមទំព័រនីមួយៗក្នុងទំព័រ៣២-៥១ សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងពីរ។



**សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ**

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្នំគ្រូព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 32 16/11/2021 08:57:16 AM

២២ មុនចាប់ផ្ដើមពន្ធកិច្ចរបស់ទ្រង់ ព្រះយេស៊ូវផ្ទាល់ទទួលបានការល្បួងពីសាតាំង ប៉ុន្តែព្រះអង្គបានតយុទ្ធនឹងសេចក្តីល្បួងរបស់សាតាំងដោយប្រើប្រាស់ប្រយោគ ចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងព្រះគម្ពីរសញ្ញាចាស់។



# សេចក្ដីល្បួងពីសាតាំង

*ម៉ាថាយ ៤:១-១១*

ក. ព្រះយេស៊ូវបានធំធាត់ឡើងក្នុងភូមិណាសារ៉ែត ជាទីកន្លែងដែលលោក យ៉ូសែប ជាឪពុកខាងឯសាច់ឈាមរបស់ទ្រង់ធ្វើការជាជាងឈើ។

ខ. នៅពេលព្រះអង្គមានព្រះជន្ម៣០ឆ្នាំ ព្រះយេស៊ូវក៏ទទួលពិធីជ្រមុជទឹកតាមរយៈលោក យ៉ូហាន-បាទីស្ទ ដែលជាហោរាដ៏ល្បីល្បាញម្នាក់របស់ព្រះជាម្ចាស់។ ហើយបន្ទាប់មក ព្រះអង្គក៏ត្រូវបានដឹកនាំដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ឲ្យចូលទៅកាន់ទីរហោស្ថានដែលនៅទីនោះព្រះអង្គបានទទួលការល្បួងពីសាតាំង។

គ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:១-៤។ តើលោកអ្នកនឹងសង្ខេបលក្ខណៈនៃសេចក្តីល្បួងទី១របស់ព្រះយេស៊ូវដោយរបៀបណា? តើព្រះអង្គបានឆ្លើយតបដោយរបៀបណា?

ឃ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:៥-៧។ តើលោកអ្នកនឹងសង្ខេបលក្ខណៈនៃសេចក្តីល្បួងទី២របស់ព្រះយេស៊ូវដោយរបៀបណា? តើព្រះអង្គបានឆ្លើយតបដោយរបៀបណា?

ង. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:៨-១១។ តើលោកអ្នកនឹងសង្ខេបលក្ខណៈនៃសេចក្តីល្បួងទី៣របស់ព្រះយេស៊ូវដោយរបៀបណា? តើព្រះអង្គបានឆ្លើយតបដោយរបៀបណា?

ច. តើការឆ្លើយតបរបស់ព្រះយេស៊ូវទៅកាន់សេចក្តីល្បួងពីសាតាំងមានចំណុចខុសគ្នាយ៉ាងដូចម្តេចពីការឆ្លើយតបរបស់នាង អេវ៉ា? សូមមើលព្រឹត្តិការណ៍ទី៥ក្នុងទំព័រ១៦។

ឆ. តើមានពាក្យអ្វីលេចឡើងក្នុងគំនិតរបស់លោកអ្នកនៅពេលដែលលោកអ្នកអានអំពីរបៀបដែលព្រះយេស៊ូវបានតយុទ្ធជាមួយនឹងសេចក្តីល្បួងពីសាតាំង?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៣២

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្តែងសេចក្តីពិត

២៣ លោក យ៉ូហាន-បាទីស្ទ ដែលជាហោរារបស់ព្រះជាម្ចាស់បានប្រកាសជាសាធារណៈថាព្រះយេស៊ូវពីស្រុកណាសារ៉ែតគឺជាស្ដេច និងព្រះអង្គសង្គ្រោះដ៏ពិសេសជាកូនចៀមរបស់ព្រះជាម្ចាស់ដែលនឹងដកនូវអំពើបាបរបស់លោកីយ៍នេះចេញ។



# ការប្រកាសរបស់លោក យ៉ូហាន-បាទីស្ទ

*យ៉ូហាន ១:២៩-៣៤, ម៉ាកុស ១*

ក. បន្ទាប់ពីបានតយុទ្ធនឹងសេចក្ដីល្បួងជាច្រើនដ៏លំបាកៗពីសាតាំង ព្រះយេស៊ូវក៏ត្រឡប់ទៅទន្លេយ័រដាន់ដែលលោក យ៉ូហាន-បាទីស្ទ កំពុងតែធ្វើពិធីជ្រមុជទឹកសម្រាប់អស់អ្នកដែលកែប្រែចិត្ត និងប្រកាសអំពីការយាងមកដល់របស់ព្រះមេស្ស៊ី។ លោក យ៉ូហាន បាននាំឲ្យពួកមហាជនមានចំណាប់អារម្មណ៍ទៅលើព្រះយេស៊ូវ ហើយក៏បានធ្វើការអំណះអំណាងដ៏គួរឲ្យកត់សម្គាល់។

ខ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១:២៩។ សូមនឹកចាំអំពីអ្វីដែលយើងបានសិក្សាទាក់ទងនឹងយញ្ញបូជាចៀមដែលប្រោសលោះអំពើបាប។ សូមមើលព្រឹត្តិការណ៍ទី១៧ក្នុងទំព័រ២៧។ តើលោកអ្នកគិតថាលោក យ៉ូហាន មានន័យយ៉ាងដូចម្ដេចតាមរយៈការប្រកាសថា «នុ៎ះន៏ កូនចៀមរបស់ព្រះ»?

គ. សូមនឹកចាំអំពីសេចក្ដីសន្យាទៅកាន់លោក អ័ប្រាហាំ ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ១២:៣ និង២២:១៨។ សូមមើលព្រឹត្តិការណ៍ទី១១ &១២ក្នុងទំព័រ២២ &២៣។ ព្រះយេស៊ូវគឺជាកូនចៅម្នាក់ពីលោក អ័ប្រាហាំ។ តើមានចំណុចភ្ជាប់គ្នាអ្វីរវាងព្រះយេស៊ូវ និងសេចក្ដីសន្យាទៅកាន់លោក អ័ប្រាហាំ?

ឃ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១:៣០-៣៤។ តើមានចំណុចពិសេសអ្វីផ្សេងណាទៀតដែលយើងរៀនបានអំពីព្រះយេស៊ូវ?



## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្ដេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្មរគ្រព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 34 16/11/2021 08:57:17 AM

២៤

មានពេលមួយ ព្រះយេស៊ូវបានប្រាប់អ្នកដឹកនាំសាសនាដ៏សំខាន់ម្នាក់ថា គាត់ត្រូវតែទទួលបទពិសោធន៍ក្នុងការកើតខាងវិញ្ញាណ ដើម្បីឲ្យអាចចូលទៅកាន់ព្រះរាជ្យនគររបស់ព្រះជាម្ចាស់បាន។



## ការជួបអ្នកដឹកនាំសាសនាម្នាក់

*យ៉ូហាន ៣:១-១៨*

ក. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៣:១-៤។ តើលោក នីកូដេម បានកាត់ស្រាយយ៉ាងដូចម្ដេចលើប្រយោគរបស់ព្រះយេស៊ូវអំពីការ «កើតជាថ្មី»?

ខ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៣:៥-៨។ តើព្រះយេស៊ូវកំពុងមានព្រះបន្ទូលអំពីការកើតជាថ្មីប្រភេទអ្វី?

គ. តើលោកអ្នកគិតថាព្រះយេស៊ូវបានមានអត្ថន័យយ៉ាងដូចម្ដេចនៅពេលដែលព្រះអង្គមានព្រះបន្ទូលអំពីតម្រូវការនៃការកើតជាថ្មីតាមរយៈព្រះវិញ្ញាណ? តម្រុយ៖ សូមត្រឡប់ទៅកាន់កណ្ឌគម្ពីរយ៉ូហានជំពូក១វិញ ហើយអានខ១០-១៣។ ពាក្យ «ព្រះអង្គ» សំដៅទៅលើព្រះយេស៊ូវ។

ឃ. សូមរម្លឹកអំពីបទពិសោធន៍របស់សាសន៍អ៊ីស្រាអែលទាក់ទងទៅនឹងពស់លង្ហិនក្នុងកណ្ឌគម្ពីរ ជនគណនា ២១:៤-៩។ សូមមើលព្រឹត្តិការណ៍ទី១៨ក្នុងទំព័រ២៩។ បន្ទាប់មក សូមអានកណ្ឌគម្ពីរ យ៉ូហាន ៣:១៤។ ចំណុចសម្គាល់៖ ងារ «កូនមនុស្ស» គឺជាការសំដៅទូទៅទៅកាន់ព្រះយេស៊ូវ។ យោងលើអ្វីដែលយើងដឹងអំពីបទពិសោធន៍របស់សាសន៍អ៊ីស្រាអែល តើលោកអ្នកគិតថាព្រះយេស៊ូវកំពុងទាយទុកអំពីអ្វីដែលនឹងកើតឡើងចំពោះព្រះអង្គ?

ង. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៣:១៥-១៨។ សូមសង្ខេបចំណុចគោលក្នុងខគម្ពីរទាំងនេះ។

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៣៤

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្ដែងសេចក្ដីពិត

២៥ មានពេលមួយទៀត ព្រះយេស៊ូវបានពន្យល់ទៅកាន់ស្ត្រីពីសាសន៍សាម៉ារីម្នាក់អំពីរបៀបដែលព្រះជាម្ចាស់ផ្គត់ផ្គង់ជាអចិន្ត្រៃយ៍នូវការស្រេកឃ្លានខាងឯព្រលឹងវិញ្ញាណរបស់នាង។



# ការជួបស្ត្រីសាសន៍សាម៉ារីម្នាក់

*យ៉ូហាន ៤:៣-៤២*

ក. នៅក្នុងសម័យកាលព្រះយេស៊ូវ គេមើលងាយពួកសាសន៍សាម៉ារី ហើយពួកសាសន៍យូដាមួយចំនួនក៏ថែមទាំងស្អប់ពួកគាត់ផងដែរ។ អ្នកដឹកនាំសាសនាក៏ថែមទាំងហាមមិនឲ្យពួកសាសន៍យូដា សូម្បីតែនិយាយជាមួយនឹងពួកគេទៀតផង។ សាសន៍យូដាបានរាប់ពួកគេថា មិនស្អាតខាងឯសាសនា។ ដោយមានចំណុចនេះនៅក្នុងគំនិត សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:៣-៩។

ខ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:១០-១៥។ តើស្ត្រីនោះកំពុងតែគិតអំពីប្រភេទទឹកបែបណា ហើយថាតើវាមានការខុសគ្នាពី «ទឹក» ដែលព្រះយេស៊ូវកំពុងតែមានបន្ទូលយ៉ាងដូចម្ដេច?

គ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:១៦-១៨។ នៅត្រង់នេះ តើយើងរៀនបានអ្វីអំពីជីវិតរបស់ស្ត្រីម្នាក់នេះ?

ឃ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:១៩-២៦។ តើព្រះយេស៊ូវបានបើកសម្ដែងព័ត៌មានអ្វីអំពីទ្រង់ទៅកាន់នាង?

ង. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:២៨-២៩។ តើព្រះយេស៊ូវអាចដឹងអំពីចំណុចជាច្រើនអំពីជីវិតរបស់ស្ត្រីម្នាក់នេះដោយរបៀបណា ខណៈពេលដែលព្រះអង្គមិនដែលធ្លាប់ជួបនាងពីមុន ហើយក៏ថ្មីក្នុងតំបន់នេះដែរ?

ច. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៤:៣០, ៣៩-៤២។ តើអ្នកស្រុកសាសន៍សាម៉ារីមួយចំនួនទៀតបានឆ្លើយតបយ៉ាងដូចម្ដេចទៅកាន់ព្រះយេស៊ូវ? តើពួកគេបានធ្វើសេចក្ដីសន្និដ្ឋានអ្វីខ្លះ?



**សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ**

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្ដេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្នងព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 36 16/11/2021 08:57:18 AM

២៦ លើសពីរបីដង ពេលព្រះយេស៊ូវ ប្រកាសថាព្រះអង្គមានភាពស្មើគ្នាជាមួយ នឹងព្រះជាម្ចាស់ នោះក៏មានមនុស្ស មួយចំនួនបានខឹងព្រះអង្គយ៉ាងខ្លាំង ហើយក៏បានព្យាយាមសម្លាប់ទ្រង់ដែរ។



## ការអះអាងរបស់ព្រះយេស៊ូវអំពីភាពជាព្រះ

*យ៉ូហាន៥:១៦-២៣; យ៉ូហាន ៨:៤៨-៥៩; យ៉ូហាន ១០:២២-៣៣*

ក. ក្នុងការដែលមនុស្សសាមញ្ញម្នាក់អះអាងថាខ្លួនជាព្រះ ឬក៏ស្មើនឹងព្រះគឺជាទម្រង់នៃការជេរប្រមាថមួយ។ ទារុណកម្មនៃការជេរប្រមាថគឺការស្លាប់ដោយចោលនឹងដុំថ្ម។

ខ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៥:១៦-២៣។ **ពិត ឬក៏មិនពិត?** *តាមរយៈការពោលជាអំណះអំណាងថាព្រះជាម្ចាស់គឺជាព្រះវរបិតារបស់ទ្រង់ នោះព្រះយេស៊ូវកំពុងតែទទួលស្គាល់ថាព្រះអង្គមានលក្ខណៈដូចជា ( និងស្មើ) ជាមួយនឹងព្រះ។*

គ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ៨:៤៨-៥៩។ នៅដើមដំបូងនៃការសិក្សារបស់យើង យើងបានសិក្សាថាព្រះអង្គមានលក្ខណៈ អស់កល្បជានិច្ច—ចាប់តាំងពីអស់កល្បជរាបដល់អស់កល្បជានិច្ច។ នៅត្រង់នេះ តើព្រះយេស៊ូវបានបើកសម្ដែងអ្វីអំពីទ្រង់ផ្ទាល់? សូមអានកណ្ឌគម្ពីរ និក្ខមនំ ៣:១៤ ហើយប្រៀបធៀបជាមួយនឹងកណ្ឌគម្ពីរ យ៉ូហាន ៨:៤៨-៥៩។ សូមមើលព្រឹត្តិការណ៍ទី១៣ ក្នុងទំព័រ២៤។

ឃ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១០:២២-៣៣។ តើពួកយូដាមានការយល់ឃើញត្រឹមត្រូវដែរឬទេ—ដែលថាព្រះយេស៊ូវកំពុងតែអះអាងថាព្រះអង្គគឺជាព្រះ?

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៣៦

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្ដែងសេចក្ដីពិត

២៧ ខណៈពេលដែលព្រះអង្គធ្វើដំណើរក្នុងចំណោមពួកគេ ជាទូទៅ ព្រះយេស៊ូវបានព្រមានដោយមានពេញទៅដោយសេចក្ដីស្រឡាញ់ និងយ៉ាងតឹងរឹងអំពីសេចក្ដីពិតនៃការដាក់ទោសដ៏នៅអស់កល្បជានិច្ចក្នុងស្ថាននរក នឹងភាពបន្ទាន់ក្នុងការគេចចេញពីវាដែរ។



## សេចក្ដីបង្រៀនអំពីស្ថាននរក

*ម៉ាកុស ៩:៤២-៤៨; លូកា ១៦:១៩-៣១*

ក. ក្នុងមេរៀនមុនៗ យើងបានសិក្សាថា បឹងភ្លើងដ៏នៅអស់កល្បជានិច្ចត្រូវបានបង្កើតឡើងសម្រាប់ជាការដាក់ទោសអារក្សនិងពួកទេវតារបស់វា។ សូមមើលព្រឹត្តិការណ៍ទី៤ក្នុងទំព័រ១៥។ សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៥:៤១។ ព្រះយេស៊ូវបានព្រមានអស់អ្នកដែលដើរតាមសាតាំងថា ពួកគេក៏នឹងទទួលបទពិសោធន៍នៃការដាក់ទោសដ៏នៅអស់កល្បជានិច្ចនេះផងដែរ។

ខ. សូមអានកណ្ឌគម្ពីរ ម៉ាកុស ៩:៤២-៤៨។ ក្នុង១៤៨ តើព្រះយេស៊ូវបានប្រើប្រាស់ប្រយោគអ្វី ដើម្បីពណ៌នាយ៉ាងច្បាស់លាស់ថា តើស្ថាននរកមានលក្ខណៈយ៉ាងដូចម្ដេច?

គ. មានពេលមួយ ព្រះយេស៊ូវបានប្រាប់អំពីបុរសម្នាក់ដែលបានស្លាប់ ហើយបានចុះទៅស្ថាននរក (ស្ថានឃុំព្រលឹង)។ សូមអានកណ្ឌគម្ពីរ លូកា ១៦:១៩-៣១។ យោងតាមអ្វីដែលព្រះយេស៊ូវបានបង្រៀន...

- **ពិត ឬក៏មិនពិត?** ស្ថាននរកគឺជាទីកន្លែងនៃការរងទុក្ខដោយដឹងខ្លួន។
- **ពិត ឬក៏មិនពិត?** បន្ទាប់ពីមនុស្សយើងបានធ្លាក់នរកហើយ ពួកគេនៅអាចគេចចេញបាន។



### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្ដេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្នងព្រះទ័យក្នុងការជំនួស

២៨ ដោយកើតចេញពីសេចក្ដីមេត្តាករុណា សម្រាប់ការបញ្ឈឺមនុស្ស និងសម្រាប់ការបង្ហាញអំណាចជាព្រះរបស់ទ្រង់ នោះព្រះយេស៊ូវក៏បានព្យាបាលអ្នកឈឺ អ្នកពិការ បណ្ដេញអារក្ស ហើយក៏ថែមទាំងប្រោសមនុស្សឲ្យរស់ពីស្លាប់ឡើងវិញផងដែរ។



# ការអស្ចារ្យរបស់ព្រះយេស៊ូវ

*ម៉ាថាយ ៤:២៣-២៤; យ៉ូហាន ១១:១-៤៥*

ក. ព្រះយេស៊ូវបានធ្វើការអស្ចារ្យជាច្រើន ដើម្បីបង្ហាញថាព្រះអង្គគឺជា «ព្រះរាជបុត្រានៃព្រះ» ដូចដែលលោក យ៉ូហាន-បាទីស្ទ បានលើកឡើង។

ខ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:២៣-២៤។ តើព្រះយេស៊ូវបានធ្វើការអស្ចារ្យដ៏ជាក់លាក់មួយណាក្នុងគ្រាដំបូងនៃព័ន្ធកិច្ចរបស់ព្រះអង្គតាមតំបន់កាលីឡេ?

គ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១១:១-៤។ តើព្រះយេស៊ូវបានមានបន្ទូលថា អ្វីទៅជាគោលបំណងដ៏ធំបំផុតក្នុងការឈឺរបស់លោកឡាសារ?

ឃ. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១១:៥-១៦។ តើព្រះយេស៊ូវបានជ្រាបអំពីអ្វីដែលពួកសិស្សរបស់ទ្រង់មិនបានដឹង?

ង. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១១:១៧-២៧។ តើព្រះយេស៊ូវបានសួរនាង ម៉ាថា អំពីអ្វីទាក់ទងនឹងជំនឿរបស់នាងលើទ្រង់? តើនាង ម៉ាថា បានឆ្លើយតបយ៉ាងដូចម្ដេច?

ច. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១១:២៨-៤៥ ហើយសូមពិនិត្យមើលដោយយកចិត្តទុកដាក់ក្នុង៖៤០-៤៥។ ក្នុងរបៀបដ៏វិជ្ជមាន តើសាសន៍យូដាជាច្រើននាក់ដែលបានឃើញការអស្ចារ្យនេះបានឆ្លើយតបយ៉ាងដូចម្ដេច? ចំណុចសម្គាល់៖ ជាទូទៅ *សាសន៍យូដា* នៃព្រះគម្ពីរសញ្ញាថ្មីគឺជាមនុស្សដូចគ្នាទៅហ្នឹង *សាសន៍អ៊ីស្រាអែល* នៃព្រះគម្ពីរសញ្ញាចាស់។

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៣៨

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្ដែងសេចក្ដីពិត

២៩

ពេលលោក យូដាស-អ៊ីស្ការីយ៉ុត (ដែលត្រូវជាសិស្សម្នាក់នៃសិស្សទាំង១២ នាក់របស់ព្រះយេស៊ូវ) បានក្បត់ព្រះអង្គ នោះព្រះយេស៊ូវក៏មិនបានតយុទ្ធហួសពីធម្មជាតិក្នុងការចាប់ ប៉ុន្តែព្រះអង្គបានចុះចូលយ៉ាងស្ម័គ្រព្រះទ័យចំពោះអ្នកដែលចាប់ទ្រង់។



# ការក្បត់ព្រះយេស៊ូវ

*ម៉ាថាយ ២៦:១-២, ១៤-២៩, ៤៥-៥៦*

ក. មុនលោកអ្នកអានចេញពីកណ្ឌគម្ពីរ ម៉ាថាយ ២៦ សូមអានទំនាយក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ៤១:៧-៩ ជាមុនសិន។

ខ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៦:១-២។ តើព្រះយេស៊ូវបានជ្រាបថានឹងមានអ្វីកើតឡើងចំពោះព្រះអង្គ?

គ. សូមអានកណ្ឌគម្ពីរ  ម៉ាថាយ ២៦:១៤-២៨។ ព្រះយេស៊ូវកំពុងតែទាយថា ព្រះកាយរបស់ទ្រង់នឹងមានការខូចបង់ ហើយព្រះលោហិតរបស់ទ្រង់នឹងមានការខ្ចាយ។ តើប្រយោគរបស់ព្រះយេស៊ូវក្នុង១២៨បានពន្យល់អំពីអ្វីដែលលោក យ៉ូហាន-បាទីស្ទលើកឡើងពីមុនដោយរបៀបណា «នុ៎ះន៏ កូនចៀមរបស់ព្រះដែលដោះបាបមនុស្សលោក!»? សូមមើលព្រឹត្តិការណ៍ទី២៣ក្នុងទំព័រ៣៤។

ឃ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៦:៤៥-៥៦។ តើព្រះយេស៊ូវមានអំណាចក្នុងការតយុទ្ធនឹងការចាប់ដែរឬទេ? តើលោកអ្នកគិតថាហេតុអ្វីបានជាព្រះអង្គបានចុះចូលដោយស្ម័គ្រព្រះទ័យនូវរូបអង្គទ្រង់ផ្ទាល់ចំពោះអ្នកមកចាប់ទ្រង់?



## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្ម័គ្រព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 40 16/11/2021 08:57:19 AM

៣០ ទោះបើថាមិនមានភស្តុតាងបង្ហាញអំពីពិរុទ្ធភាពនៃការធ្វើខុសក្នុងតុលាការសាសនា ឬក៏ច្បាប់នៃពលរដ្ឋក៏ដោយ ក៏គេបានវាយព្រះអង្គយ៉ាងអយុត្តិធម៌ ហើយក៏បានថ្កោលទោសឲ្យព្រះអង្គសុគតតាមរយៈការឆ្កាងបែបសាសន៍រ៉ូម។



# ការកាត់ទោសព្រះយេស៊ូវដោយចៅក្រមអយុត្តិធម៌

*ម៉ាថាយ ២៧:១-២, ១១-២៤*

ក. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៧:១-២។ ត្រង់នេះ តើមានការសម្គាល់ពីមុនៗយ៉ាងដូចម្ដេចដែលថាព្រះយេស៊ូវនឹងមិនទទួលបានការកាត់ទោសថាយ៉ាងយុត្តិធម៌?

ខ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៧:១១-១៤។ តើព្រះយេស៊ូវបានបដិសេធពាក្យចោទប្រកាន់ដែលថា ព្រះអង្គជាស្ដេចនៃសាសន៍យូដាដែរឬទេ?

- ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៤៩:១០ ព្រះជាម្ចាស់បានសន្យាថា ដំបងរាជ្យដែលជាសញ្ញាសម្គាល់នៃខ្សែស្ដេចនិងមិនដែលចាកចេញពីកុលសម្ព័ន្ធនៃសាសន៍យូដាទេ។ ក្នុងនាមជាខ្សែនៃពង្សាវតារក្សត្រនៃសាសន៍យូដា ព្រះយេស៊ូវមានសិទ្ធិក្នុងការធ្វើជាស្ដេចនៃពួកយូដាបាន។ សូមរម្លឹកចំណុច ឃ. ក្នុងព្រឹត្តិការណ៍ទី១២ក្នុងទំព័រ២៣។
- សូមរម្លឹកចំណុច ខ. គ. និង ឃ. ក្នុងព្រឹត្តិការណ៍ទី១៩ក្នុងទំព័រ៣០។ ក្នុងនាមជាខ្សែនៃពង្សាវតារក្សត្រនៃស្ដេច ដាវីឌ ដែលជាអង្គពីកុលសម្ព័ន្ធនៃសាសន៍យូដា នោះព្រះយេស៊ូវក៏មានសិទ្ធិក្នុងការបង្កើតឡើងវិញនូវការសោយរាជ្យនៃខ្សែស្ដេចនៃពង្សាវតារក្សត្រនៃស្ដេច ដាវីឌ បានផងដែរ។

គ. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៧:១៥-២៤។ ក្នុងបទគម្ពីរនេះ តើយើងឃើញថាមានភស្តុតាងអ្វីដែលបញ្ជាក់ថា ព្រះយេស៊ូវមិនមានពិរុទ្ធភាពទាក់ទងនឹងបទឧក្រិដ្ឋដែលគេកំពុងតែចោទលើ?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៤០

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្ដែងសេចក្ដីពិត

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 41 16/11/2021 08:57:19 AM

៣១ បន្ទាប់មក ព្រះយេស៊ូវក៏សុគតលើឈើឆ្កាងជាចៀមនៃយញ្ញបូជាដ៏ល្អឥតខ្ចោះរបស់យើង ហើយក៏បានបំផ្លាញសាតាំងដូចដែលព្រះជាម្ចាស់បានសន្យាទៅកាន់លោក អ័ដាម និងនាង អេវ៉ា។



# ការឆ្កាងព្រះយេស៊ូវ

*លូកា ២៣:២៦-៣៨;*
*១កូរិនថូស ៥:៧*

ក. លោក ជូស៊ីហ្វើស៍ ( Josephus ) ដែលជាប្រវត្តិវិទូម្នាក់នៃសាសន៍យូដាបានពណ៌នាការឆ្កាងថា «គឺជាការស្លាប់ដ៏អាក្រក់បំផុត»។ ជាដំបូង អ្នកទោសត្រូវបានគេវាយដោយគ្មានចិត្តមេត្តាជាមួយនឹងខ្សែតីដ៏ខ្លី ហើយធ្ងន់មួយ។ បន្ទាប់មក គេក៏យកដែកគោលដំគាត់ភ្ជាប់លើឈើឆ្កាង ហើយគាត់ក៏ទទួលការរងទុក្ខដ៏អាម៉ាស់ និងមានពេញទៅដោយការឈឺចាប់ជាច្រើនម៉ោងមុនការឆ្កាងដ៏តឹងរឹងនេះឈានដល់ទីបញ្ចប់ ពោលគឺការស្លាប់។

ខ. សូមអានកណ្ឌគម្ពីរ ទំនុកតម្កើង ២២:១-១៨។ ស្តេច ដាវីឌ បាននិពន្ធទំនុកនេះអំពីព្រះមេស្ស៊ីនៃសាសន៍យូដាជាប្រមាណ ១០០០ឆ្នាំមុនព្រះយេស៊ូវបានប្រសូតមក និងរាប់រយឆ្នាំមុនគេចាប់ផ្តើមប្រើប្រាស់ការឆ្កាងជាទារុណកម្មនៃការសម្លាប់នៅស្រុកកាណាន។ សូមកត់សម្គាល់លើចំណុចដែលថាបុរស ( ព្រះមេស្ស៊ី) ដែលកំពុងតែមានការពណ៌នាលើនៅត្រង់នេះនឹងស្លាប់ដោយការឆ្កាង។

គ. សូមអានកណ្ឌគម្ពីរ លូកា ២៣:២៦-៣៨។ តើសេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវក្នុងខ៣៤ប្រាប់យើងអ្វីខ្លះអំពីទ្រង់?

ឃ. សូមអានប្រយោគចុងក្រោយក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៥:៧ ហើយគិតអំពីចំណុចស្រដៀងៗគ្នារវាងកូនចៀមនៃញបូជានៅថ្ងៃបុណ្យរំលងដែលត្រូវបានសម្លាប់នៅប្រទេសអេស៊ីព្ទ និងការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង។ សូមមើលព្រឹត្តិការណ៍ទី១៤ក្នុងទំព័រ២៥។

## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

ទំព័រ ៤១

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្នងព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 42 16/11/2021 08:57:20 AM

៣២ ខណៈពេលដែលព្រះយេស៊ូវកំពុងតែសុគត មានបុរសពិរុទ្ធម្នាក់ដែលត្រូវបានគេឆ្កាង នៅក្បែរព្រះអង្គបានដាក់ជំនឿរបស់គាត់លើព្រះយេស៊ូវ ហើយព្រះអង្គក៏បានប្រទានអំណោយទាននៃជីវិតនៅឯស្ថានបរមសុខបន្ទាប់ពីស្លាប់ទៅ។



## ការកែប្រែចិត្តរបស់ចោរម្នាក់ដែលកំពុងស្លាប់

*លូកា ២៣:៣៩-៤៧*

ក. សូមអានកណ្ឌគម្ពីរ លូកា ២៣:៣៩-៤២។ តើចំណុចមួយណាក្នុងចំណុចទាំងអស់នេះដែលជាចំណុចពិតទាក់ទងនឹងជនឧក្រិដ្ឋដែលបានកែប្រែចិត្ត?

- ☐ គាត់កោតខ្លាចព្រះ។
- ☐ គាត់ទទួលស្គាល់ពិរុទ្ធភាពរបស់គាត់។
- ☐ គាត់ទទួលស្គាល់ការដែលព្រះយេស៊ូវគ្មានទោស។
- ☐ គាត់ជឿថា ព្រះយេស៊ូវគឺជាស្តេចដ៏ពិតមួយអង្គ។
- ☐ គាត់ជឿថា មានជីវិតបន្ទាប់ពីការស្លាប់ទៅ។
- ☐ គាត់ជឿថា ព្រះយេស៊ូវអាចដាក់ការពេញចិត្តមួយប្រភេទនៃព្រះរាជ្យនគរនៅលើគាត់បាន។
- ☐ គាត់បានធ្វើសំណើរដ៏សាមញ្ញមួយដែលមានជំនឿជាមូលដ្ឋានលើព្រះយេស៊ូវ។

ខ. សូមអានកណ្ឌគម្ពីរ លូកា ២៣:៤៣។ សូមពិភាក្សាអំពីអ្វី ពេលវេលា និងភាពប្រាកដប្រជានៃសេចក្តីសន្យារបស់ព្រះយេស៊ូវ។

គ. តើព្រះជាម្ចាស់បានប្រទានស្ថានបរមសុខបែបណាផ្សេងទៀតពីមុនក្នុងព្រះគម្ពីរ? សូមមើលព្រឹត្តិការណ៍ទី៣ក្នុងទំព័រ១៤។

ឃ. សូមអានកណ្ឌគម្ពីរ លូកា ២៣:៤៤-៤៧។ តើមេទ័ពនៃសាសន៍រ៉ូមម្នាក់បានធ្វើសេចក្តីសន្និដ្ឋានអ្វី?

ង. សូមអានកណ្ឌគម្ពីរ ម៉ាកុស ១៥:៣៣-៣៩។ តើមានសេចក្តីពិតណាមួយផ្សេងទៀតក្នុងប្រវត្តិសាស្រ្តដែលមាននៅត្រង់នេះទាក់ទងនឹងការសុគតរបស់ព្រះយេស៊ូវ?

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្តែងសេចក្តីពិត

៣៣ នៅថ្ងៃទី៣ បន្ទាប់ពីព្រះយេស៊ូវបានសុគត ហើយត្រូវបានគេបញ្ចុះក្នុងផ្នូរ នោះព្រះជាម្ចាស់ក៏បានប្រោសទ្រង់បែបអធម្មជាតិឲ្យមានព្រះជន្មរស់ពីការសុគតឡើងវិញ ដើម្បីបង្ហាញនូវអំណាចរបស់ព្រះអង្គលើអំពើបាប សេចក្តីស្លាប់ និងស្ថាននរក។



## ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ

*លូកា ២៤:១-១២, ៣៦-៤៣*

ក. សូមអានកណ្ឌគម្ពីរ ហេព្រើរ ២:១៤-១៥។ ក្នុងខ១៤ តើយើងឃើញអំពីគោលបំណងនៃការសុគតរបស់ព្រះយេស៊ូវដោយរបៀបណាខ្លះ? ក្នុងខ១៥?

ខ. សូមអានកណ្ឌគម្ពីរ លូកា ២៤:១-១២។ សូមស្វែងរកភស្តុតាងដែលបញ្ជាក់ថា មិនមានព្រះយេស៊ូវនៅក្នុងផ្នូរទៀតទេ។

គ. សូមអានកណ្ឌគម្ពីរ លូកា ២៤:៣៦-៤៣។ តើព្រះយេស៊ូវបានធ្វើអ្វី ដើម្បីបង្ហាញថាព្រះអង្គមិនមែនគ្រាន់តែជាវិញ្ញាណ—ដែលថារូបកាយខាងឯសាច់ឈាមរបស់ព្រះអង្គត្រូវបានប្រោសឲ្យរស់ពីការសុគតឡើងវិញហើយ?

ឃ. ដោយសារព្រះជាម្ចាស់បានប្រោសព្រះយេស៊ូវពីសុគតឡើងវិញ...

- **ពិត ឬក៏មិនពិត?** យើងអាចមានទំនុកចិត្តថា អ្វីដែលព្រះយេស៊ូវបានមានព្រះបន្ទូលអំពីព្រះអង្គគឺជាការពិតមែន។
- **ពិត ឬក៏មិនពិត?** យើងអាចមានទំនុកចិត្តថា ព្រះជាម្ចាស់មានការស្កប់ស្កល់ព្រះហឫទ័យជាមួយនឹងការសុគតរបស់ព្រះយេស៊ូវ ក្នុងនាមជាការបង់ថ្លៃសម្រាប់អំពើបាបរបស់យើង។

ង. ខណៈពេលដែលលោកអ្នកគិតត្រឡប់បកក្រោយវិញអំពីអ្វីដែលយើងបានសិក្សារួចហើយ តើលោកអ្នកនឹងឆ្លើយសំណួរនេះដោយរបៀបណា៖ តើព្រះយេស៊ូវជានរណា? ទស្សនៈវិទូដ៏ឆ្នើមម្នាក់ខាងផ្នែកការរិះគន់អក្សរសាស្ត្របានលើកឡើងថាមានជម្រើសតែបីយ៉ាងប៉ុណ្ណោះ៖

- ☐ ព្រះអង្គជាមនុស្សឆ្កួត។
- ☐ ព្រះអង្គជាមនុស្សកុហក។
- ☐ ព្រះអង្គជាព្រះអម្ចាស់ដូចដែលទ្រង់បានមានបន្ទូល។



**សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ**

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្ម័គ្រព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 44 16/11/2021 08:57:21 AM

៣៤ បន្ទាប់ពីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូវបានលេចឡើងជាច្រើនលើកច្រើនសារនៅលើផែនដីនេះចំពោះពួកសិស្សរបស់ព្រះអង្គ ហើយបន្ទាប់មកព្រះអង្គក៏បានយាងទៅឯស្ថានសួគ៌ ដើម្បីគង់នៅជាមួយនឹងព្រះវរបិតារបស់ទ្រង់។



## ការដែលព្រះយេស៊ូវយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ

*១កូរិនថូស ១៥:៣-៨;*
*កិច្ចការ ១:៦-១១*

ក. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:៣-៨។ **ពិត ឬក៏មិនពិត?** *ប្រមាណលើសជាងមនុស្ស៥០០នាក់បានឃើញព្រះយេស៊ូវមានព្រះជន្ម បន្ទាប់ពីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ ក្នុងចំនួនពួកគេក៏មានមនុស្សជាច្រើននៅរស់នៅឡើយពេលដែលសំបុត្រនៃកណ្ឌគម្ពីរកូរិនថូសត្រូវបានសរសេរឡើង។*

ខ. សូមអានកណ្ឌគម្ពីរ កិច្ចការ ១:៦-៨។ កណ្ឌគម្ពីរ កិច្ចការ ១:៨ សរសេរចុះនូវព្រះបន្ទូលចុងក្រោយដែលព្រះយេស៊ូវបានលើកឡើងនៅលើផែនដីនេះ។ សូមសង្ខេបប្រយោគចុងក្រោយដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់អ្នកដើរតាមទ្រង់។

គ. សូមអានកណ្ឌគម្ពីរ កិច្ចការ១:៩-១១។ តើបុរស (ទេវតា) ទាំងពីរនាក់បានសន្យាអ្វីចំពោះអ្នកដើរតាមព្រះយេស៊ូវ?

ឃ. បន្ទាប់ពីពេលដែលព្រះយេស៊ូវបានលេចឡើងក្នុងដំណើររឿងនៃព្រះគម្ពីរគឺត្រូវបានសរសេរឡើងក្នុងប្រមាណជំពូកក្រោយមក។ សូមអានកណ្ឌគម្ពីរ កិច្ចការ ៧:៥៤-៥៦។ នៅពេលនោះ តើព្រះយេស៊ូវកំពុងតែគង់នៅកន្លែងណា?

ង. ឥឡូវនេះ តើព្រះយេស៊ូវកំពុងតែធ្វើអ្វីនៅឯស្ថានសួគ៌? សូមអានកណ្ឌគម្ពីរ ហេព្រើរ ៧:២៤-២៥។ តម្រុយ៖ ពាក្យ «ព្រះអង្គ» (មានក្នុងការបកប្រែទានានៃព្រះគម្ពីរ) សំដៅទៅលើព្រះយេស៊ូវ។

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៤៤

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្តែងសេចក្តីពិត

៣៥ បន្ទាប់ពីព្រះយេស៊ូវបានយាងទៅឯស្ថានសួគ៌ នោះពួកសិស្សរបស់ព្រះអង្គក៏បានចាប់ផ្តើមប្រកាសដំណឹងល្អអំពីចំណុចដែលថា តើព្រះយេស៊ូវជានរណា តើព្រះអង្គបានធ្វើអ្វី ហើយហេតុអ្វីបានជាពួកមនុស្សម្នាគួរតែជឿទុកចិត្តលើទ្រង់ ក្នុងនាមជាព្រះអង្គសង្គ្រោះរបស់ខ្លួន។



# សាវ័ក ពេត្រុស ប្រកាសដំណឹងល្អ

*កិច្ចការ ២:២២-៣៦*

ក. ដប់ថ្ងៃបន្ទាប់ពីព្រះយេស៊ូវបានយាងទៅកាន់ស្ថានសួគ៌វិញ នោះព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ក៏បានយាងមកសណ្ឋិតលើអ្នកដើរតាមព្រះយេស៊ូវ ដូចដែលព្រះអង្គបានសន្យា។

ខ. ដោយមានអំណាចព្រះចេស្តានៃព្រះវិញ្ញាណនៃព្រះលើគាត់ នោះសិស្សម្នាក់ក្នុងចំណោមសិស្សទាំងឡាយរបស់ព្រះយេស៊ូវ (ស៊ីម៉ូន-ពេត្រុស) ក៏បានប្រកាសសារដំបូងរបស់គាត់អំពីព្រះយេស៊ូវ។ ដោយសំអាងលើអ្វីដែលគាត់បានឃើញ និងឮផ្ទាល់៖ តើសាវ័ក ពេត្រុស បានលើកឡើងអ្វីខ្លះអំពីព្រះយេស៊ូវ? សូមអានកណ្ឌគម្ពីរ កិច្ចការ ២:២២-៣៥។

- *ព្រះជន្មរបស់ទ្រង់ (ខ២២)*

- *ការសុគតរបស់ទ្រង់ (ខ២៣)*

- *ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ (ខ២៤-៣២)* សូមសម្គាល់៖ សាវ័ក ពេត្រុស បានលើកកណ្ឌគម្ពីរ ទំនុកតម្កើង ១៦:៨-១០ ជាសម្រង់សម្តីយោងក្នុងខ២៥-២៨។ សូមចងចាំថាទំនុកមួយនេះត្រូវបាននិពន្ធឡើងដោយស្តេច ដាវីឌ ប្រមាណជា១០០០ឆ្នាំមុនការដែលព្រះយេស៊ូវមានព្រះជន្មនៅលើផែនដីនេះ។

- *ការយាងទៅឯស្ថានសួគ៌របស់ទ្រង់ (ខ៣៣-៣៥)*

គ. តើអ្វីទៅជាសេចក្តីសន្និដ្ឋានសរុបរបស់សាវ័ក ពេត្រុស អំពីព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែត? សូមអានខ៣៦។



## សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្នងព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 46 16/11/2021 08:57:21 AM

៣៦

ដូចដែលព្រះអង្គបានសន្យាកាលទ្រង់កំពុងតែធ្វើព័ន្ធកិច្ចនៅលើផែនដី នោះព្រះយេស៊ូវក៏នឹងត្រឡប់មកវិញ ដើម្បីយកអស់អ្នកដែលពិតជាជឿលើព្រះអង្គ ដើម្បីឲ្យនៅជាមួយទ្រង់នៅឯស្ថានសួគ៌ដែលជាស្ថានបរមសុខ។



## ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវសម្រាប់អ្នកជឿ

*យ៉ូហាន ១៤:១-៣;*
*១ថែស្សាឡូនីច ៤:១៣-១៨*

ក. ដោយមានការចាប់ផ្ដើមក្នុងព្រឹត្តិការណ៍នេះ ព្រឹត្តិការណ៍ចុងក្រោយទាំងប្រាំក្នុងការសង្ខេបនៃដំណើររឿងបែបជារូបភាពធំនៃព្រះគម្ពីរនេះមិនទាន់បានកើតឡើងនៅឡើយទេ។ មកដល់ពេលនេះ ជាគោលយើងទើបតែបានសិក្សាប្រវត្តិសាស្ត្រព្រះគម្ពីរប៉ុណ្ណោះ។ ប៉ុន្តែឥឡូវនេះ ដោយគ្មានការជាប់រដឹក នោះយើងនឹងឃើញថា ព្រះគម្ពីរបានចាកចេញពីប្រវត្តិសាស្ត្រព្រះគម្ពីរ (ព្រឹត្តិការណ៍ពីអតីតកាល) ហើយឈានចូលទៅក្នុងទំនាយព្រះគម្ពីរ (ព្រឹត្តិការណ៍នៅអនាគតកាល)។

ខ. មុនព្រះអង្គសុគត តើព្រះយេស៊ូវបានប្រាប់អ្វីទៅកាន់ពួកសិស្សរបស់ទ្រង់ ដើម្បីជាការកំសាន្តចិត្តដល់ពួកគេ? សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៤:១-៣។

គ. ដើម្បីរៀនបន្ថែមទៀតអំពីការយាងត្រឡប់មកវិញនេះរបស់ព្រះយេស៊ូវសម្រាប់អ្នកជឿ សូមអានកណ្ឌគម្ពីរ ១ថែស្សាឡូនីច ៤:១៣-១៨។

- តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលដើរតាមព្រះយេស៊ូវដែលបានស្លាប់រួចបាត់ទៅហើយ?

- តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលដើរតាមព្រះយេស៊ូវដែលនៅរស់នៅឡើយ ពេលទ្រង់យាងត្រឡប់មកវិញ?

ឃ. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:៥១-៥៧។ ត្រង់នេះ តើមានព័ត៌មានបន្ថែមអ្វីទាក់ទងនឹងការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវគ្រីស្ទ?

### ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៤៦

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្ដែងសេចក្ដីពិត

៣៧ មិនយូរប៉ុន្មានបន្ទាប់ពីព្រះអង្គយាងមកយកអ្នកជឿ នោះព្រះយេស៊ូវនឹងយាងត្រឡប់មកវិញជាមួយអស់អ្នកដែលព្រះអង្គបានយកទៅឯស្ថានសួគ៌ ហើយព្រះអង្គនឹងសោយរាជ្យក្នុងនាមជាស្តេចលើផែនដីទាំងមូល។



## ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវក្នុងនាមជាស្តេច

*វិវរណៈ:១៩:១១-១៩;*
*វិវរណៈ: ២០:១-៦*

ក. សូមចាំថាអក្សរសាស្ត្រនៃកណ្ឌគម្ពីរវិវរណៈមានការប្រើប្រាស់និមិត្តសញ្ញាយ៉ាងខ្លាំង។ ប៉ុន្តែ បន្ទាប់ពីយើងមើលខាងក្រោមពាក្យពេចន៍នៃនិមិត្តសញ្ញា នោះយើងនឹងឃើញថាមានសេចក្តីពិតបម្លង់ៗ៤យ៉ាង។ សូមអានកណ្ឌគម្ពីរ វិវរណៈ: ១៩:១១-១៩។

- ព្រះយេស៊ូវនឹងយាងត្រឡប់មកផែនដីវិញ។ ( តើយើងដឹងដោយរបៀបណាថា នេះគឺជាព្រះយេស៊ូវដែលយើងបានរៀនអំពី? )

- ពួកពលបរិវារនៃស្ថានសួគ៌នឹងមកជាមួយនឹងព្រះយេស៊ូវ ( តើមានអ្នកណាខ្លះក្នុងពួកពលបរិវារនេះ? )

- នៅពេលនោះ ព្រះយេស៊ូវនឹងយកឈ្នះលើអស់អ្នកដែលទាស់ប្រឆាំងនឹងទ្រង់។ ( តើអ្នកណាទៅជាខ្មាំងសត្រូវទាំងអស់នោះរបស់ព្រះយេស៊ូវ? )

- ក្នុងការធ្វើបែបនេះ នោះសេចក្តីក្រោធរបស់ព្រះជាម្ចាស់នឹងមានការអនុម័តឡើងដោយយុត្តិធម៌។ ( ហេតុអ្វីបានជាការថ្កោលទោសនេះយុត្តិធម៌ ហើយនិងត្រឹមត្រូវ? )

ខ. សូមអានកណ្ឌគម្ពីរ វិវរណៈ: ២០:១-៣។ តើ «ពស់ពីចាស់បុរាណ» ជាអ្នកណា ហើយតើនឹងមានអ្វីកើតឡើងចំពោះវា? សូមមើលព្រឹត្តិការណ៍ទី៤, ៥, និង៧ក្នុងទំព័រ១៥, ១៦, និង១៨។

គ. សូមអានកណ្ឌគម្ពីរ វិវរណៈ: ២០:៤-៦។ តើនឹងមានអ្វីកើតឡើងលើផែនដីនេះអស់រយៈពេល១០០០ឆ្នាំ? ក្នុងការសិក្សារបស់យើង តើយើងបានឃើញអំពីការទាយទុកនេះដែលថាព្រះយេស៊ូវនឹងសោយរាជ្យជាស្តេចនៅត្រង់ណា?



### សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្មុំគ្រព្រះទ័យក្នុងការជំនួស

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 48 16/11/2021 08:57:22 AM

៣៨

ក្រោយមកទៀត បន្ទាប់ពីការព្យាយាមជាលើកចុងក្រោយ ក្នុងការដឹកនាំការបោះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់នៅជិតគ្រាចុងក្រោយនៃនគរលើផែនដីរបស់ព្រះយេស៊ូវ នោះព្រះជាម្ចាស់នឹងទម្លាក់សាតាំងឲ្យធ្លាក់ក្នុងបឹងភ្លើងដែលព្រះអង្គបានរៀបចំទុកជាមុនសម្រាប់វា។



# សេចក្តីវេទនាចុងក្រោយរបស់សាតាំង

*វិវរណៈ ២០:៧-១០*

ក. មុនសេចក្តីវិនាសចុងក្រោយនេះកើតឡើង នោះសាតាំងនឹងត្រូវជាប់ឃុំអស់រយៈពេល១០០០ឆ្នាំ។ សូមអានកណ្ឌគម្ពីរ វិវរណៈ:២០:១-៣។

ខ. នៅពេល១០០០ឆ្នាំឈានដល់ទីបញ្ចប់ នោះសាតាំងនឹងទទួលការប្រលែងជាបណ្តោះអាសន្នសិន។ តើសាតាំងនឹងធ្វើអ្វីនៅពេលនោះ? សូមអានកណ្ឌគម្ពីរ វិវរណៈ: ២០:៧-៩។

គ. សូមអាន និងរម្លឹកកណ្ឌគម្ពីរ អេសាយ ១៤:១៥ និងកណ្ឌគម្ពីរ ម៉ាថាយ ២៥:៤១។ សូមមើលព្រឹត្តិការណ៍ទី៤ក្នុងទំព័រ១៥។ ហើយសូមអានកណ្ឌគម្ពីរ វិវរណៈ: ២០:១០។ នៅត្រង់នេះ តើយើងរៀនបានអ្វីអំពីលក្ខណៈនៃការដាក់ទារុណកម្មចុងក្រោយរបស់សាតាំង?

ឃ. សូមអាន និងរម្លឹកកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥។ សូមមើលព្រឹត្តិការណ៍ទី៧ក្នុងទំព័រ១៧។ តើមានចំណុចតភ្ជាប់អ្វីរវាងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥ (ក្នុងជំពូកទី៣នៃព្រះគម្ពីរ) និងសេចក្តីវិនាសចុងក្រោយរបស់សាតាំងដែលមានពណ៌នានៅត្រង់នេះ (ក្នុងជំពូកទី៣ពីកណ្ឌគម្ពីរចុងក្រោយនៃព្រះគម្ពីរ)?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖

ទំព័រ ៤៨

☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្តែងសេចក្តីពិត

៣៩ បន្ទាប់មក នៅគ្រាចុងក្រោយនៃផែនដីនេះ ដូចដែលយើងបានដឹងអំពីវា នោះអ្នកមិនជឿនឹងត្រូវឈរនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់ ដើម្បីទទួលការកាត់ក្តីនៃការដាក់ទារុណកម្មដ៏នៅអស់កល្បជានិច្ច សម្រាប់អំពើបាបរបស់ពួកគេ។



## វាសនាដ៏អាក្រក់សម្រាប់អ្នកមិនជឿ

*វិវរណៈ ២០:១១-១៥*

ក. ខណៈពេលដែលព្រឹត្តិការណ៍នេះចាប់ផ្តើម តើនឹងមានអ្វីកើតឡើងចំពោះផែនដី និងផ្ទៃមេឃនៅបច្ចុប្បន្ននេះ? សូមអានកណ្ឌគម្ពីរ វិវរណៈ ២០:១១ ហើយប្រៀបធៀបជាមួយនឹងកណ្ឌគម្ពីរ ២ពេត្រុស ៣:១០។

ខ. តើលោកអ្នកគិតថានរណាជាចៅក្រមលើបល្ល័ង្កសដ៏ធំមួយនេះ? សូមពិភាក្សាលើសំណួរ ហើយបន្ទាប់មកសូមអានកណ្ឌគម្ពីរ យ៉ូហាន ៥:២២-២៣។

គ. បញ្ជីទាំងនេះនឹងមានតួនាទីដ៏សំខាន់ៗ នៅពេលដែលអ្នកមិនជឿឈរចំពោះព្រះភក្ត្រចៅក្រម ខណៈពេលដែលព្រះអង្គគង់នៅលើបល្ល័ង្កសមួយយ៉ាងធំ។ សូមអានកណ្ឌគម្ពីរ វិវរណៈ ២០:១២-១៣។

- តើអ្វីទៅជាតួនាទីនៃ «បញ្ជី» ទាំងនេះ?
- តើអ្វីទៅជាតួនាទីនៃ «បញ្ជីជីវិត»? (ខ១៤-១៥)

ឃ. សូមអានកណ្ឌគម្ពីរ វិវរណៈ ២០:១៤-១៥។ តើអ្នកណានឹងត្រូវបោះទៅក្នុងបឹងភ្លើង?

- យោងតាមខ១៤?
- យោងតាមខ១៥?



សូមគូសចំណាំលើចំណុចនីមួយៗនៃរបៀបដែលបង្ហាញអំពីព្រះយេស៊ូវ

☐ មនុស្សដែលបន្ទាបខ្លួន ☐ មនុស្សដែលគ្មានបាប ☐ គ្រូបង្រៀនដែលមានអំណាច ☐ ព្រះដ៏ជាមនុស្ស
☐ អ្នកធ្វើការអស្ចារ្យ ☐ ព្រះមេស្ស៊ីដែលគេបដិសេធ ☐ ស្តេចនៃសាសន៍អ៊ីស្រាអែលដែលត្រូវបានសន្យាថានឹងមក ☐ ស្មុំគ្រព្រះទ័យក្នុងការជំនួស

៤០ ប៉ុន្តែ សាច់រឿងរបស់ព្រះជាម្ចាស់មានការបញ្ចប់ដោយមានដំណឹងដ៏ល្អ។—អស់អ្នកណាដែលបានទុកចិត្តលើព្រះយេស៊ូវថាជាព្រះអង្គសង្គ្រោះរបស់ខ្លួននឹងចូលទៅរស់នៅជាមួយនឹងព្រះជាម្ចាស់ដ៏នៅអស់កល្បជានិច្ចក្នុងស្ថានបរមសុខដែលគ្មានអំពើបាប ហើយយ៉ាងស្រស់ស្អាតបំផុត។



# វាសនាដ៏មានសុភមង្គលសម្រាប់អ្នកជឿ

*វិវរណៈ ២១:១-២២:៥*

ក. ដើម្បីឲ្យអ្នកជឿអាចមានអំណរសប្បាយក្នុងស្ថានបរមសុខដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់បាន...

☐ នោះពួកគេនឹងត្រូវទៅឯស្ថានសួគ៌សម្រាប់ទទួលយកវា ឬក៏...

☐ ព្រះជាម្ចាស់នឹងនាំទីកន្លែងនោះចុះមកសម្រាប់ពួកគេ។ សូមអានកណ្ឌគម្ពីរ វិវរណៈ:២១:១-៣ ដើម្បីទទួលបានចម្លើយ។

ខ. សូមអានកណ្ឌគម្ពីរ វិវរណៈ: ២១:៤-២២:៥ ដើម្បីរៀនបន្ថែមទៀតអំពីស្ថានបរមសុខនេះ។

- តើ «កូនចៀម» ជានរណា? តម្រុយ៖ សូមមើល១១៤។
- តើនឹងមិនឃើញមានអ្វីនៅក្នុងទីក្រុងថ្មី និងទីក្រុងបរិសុទ្ធ?
- តើមានលក្ខណៈពិសេសដ៏គួរឲ្យចាប់អារម្មណ៍អ្វីខ្លះក្នុងទីក្រុងថ្មីនេះ?
- តើអ្នកណានឹងទទួលបានការអនុញ្ញាតឲ្យរស់នៅក្នុងស្ថានបរមសុខថ្មីនេះ? សូមអានកណ្ឌគម្ពីរ វិវរណៈ: ២១:២៧។

គ. តើពួកគេនឹងរស់នៅទីនោះអស់រយៈពេលយូរប៉ុណ្ណា? សូមអានកណ្ឌគម្ពីរ វិវរណៈ: ២២:៥។

ឃ. តើលោកអ្នកគិតថាឈ្មោះរបស់លោកអ្នកត្រូវបានមានសរសេរចុះក្នុងបញ្ជីជីវិតរបស់កូនចៀមដែរឬទេ?

☐ បាទ/ចាស ☐ ទេ ☐ មិនប្រាកដ

តើលោកអ្នកធ្វើសេចក្តីសន្និដ្ឋាននេះដោយរំពឹងលើមូលដ្ឋានអ្វី?

## ក្នុងព្រឹត្តិការណ៍ទាំងនោះលើទំព័រទាំងនេះ៖



☐ យញ្ញបូជាដ៏ល្អឥតខ្ចោះ ☐ អ្នកអត់ទោសអំពើបាប ☐ ព្រះសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ☐ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលយាងទៅស្ថានសួគ៌វិញ ☐ អ្នកយកឈ្នះលើសាតាំង ☐ កូនចៀមនៃព្រះដែលគេថ្វាយបង្គំ ☐ អ្នកសម្តែងសេចក្តីពិត

The Story Translaated In Khmer -15.02.2021-Ro 3.0.indd 51 16/11/2021 08:57:23 AM

# សេចក្តីពិតសំខាន់៨យ៉ាងដែលកើត

## ព្រះជាម្ចាស់

*អ្វីដែលយើងរៀនបានអំពីព្រះអាទិករ
របស់យើង៖*

១. ព្រះនៃព្រះគម្ពីរមានព្រះជន្មជាអចិន្ត្រៃយ៍ ហើយក៏នឹងបន្តមានព្រះជន្មយ៉ាងអស់កល្បជានិច្ច។ ដោយសារព្រះអង្គមានព្រះជន្មយ៉ាងអស់កល្បជានិច្ច ដូច្នេះព្រះអង្គក៏ហៅរូបអង្គទ្រង់ថា «អញជាព្រះដ៏ជាព្រះ» ដែលព្រះគម្ពីរខ្មែរយើងបកប្រែថា «ព្រះយេហូវ៉ា»។

២. ដោយគ្រាន់តែតាមរយៈការបញ្ជាឲ្យកើតឡើង នោះព្រះជាម្ចាស់ក៏បានបង្កើតផែនដី និងរាល់គ្រប់អ្វីៗទាំងអស់។ នៅក្នុងសណ្ឋានដើមរបស់វា ការបង្កើតរបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ។

៣. ក្នុងព្រះគម្ពីរទាំងមូល ព្រះអាទិករមួយអង្គនេះក៏បានបន្តបង្ហាញម្តងហើយម្តងទៀតថា ព្រះអង្គមានពេញទៅដោយអំណាចព្រះចេស្តា។

៤. ក្នុងភាពផ្ទុយគ្នាជាមួយនឹងព្រះក្លែងក្លាយ ព្រះដ៏ពិតគឺបរិសុទ្ធល្អឥតខ្ចោះ (គឺគ្មានអំពើបាបទេ)។

៥. ក្នុងនាមជាព្រះអាទិករនៃមនុស្សជាតិ ព្រះជាម្ចាស់បានប្រទានដល់មនុស្សប្រុស និងមនុស្សស្រីនូវការបញ្ជាដ៏ច្បាស់លាស់ឲ្យស្តាប់បង្គាប់។

៦. ព្រះជាម្ចាស់គឺជាចៅក្រមដ៏សុចរិត ហើយត្រឹមត្រូវ ដូច្នេះព្រះអង្គត្រូវតែ ហើយក៏នឹងដាក់ទារុណកម្មលើការមិនស្តាប់បង្គាប់។

៧. ព្រះជាម្ចាស់នៅស្រឡាញ់យើង សូម្បីតែនៅពេលដែលយើងមិនស្តាប់បង្គាប់ព្រះអង្គក៏ដោយ។

**តើសេចក្តីពិតមួយណាអំពីព្រះជាម្ចាស់ដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




១

**ព្រះគម្ពីរបានចែងថា៖** *ប៉ុន្តែ បើឥតមានជំនឿទេ នោះមិនអាចគាប់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅជិតព្រះ ត្រូវតែជឿថា ពិតជាមានព្រះមែន ហើយថា ព្រះអង្គប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកព្រះអង្គ។* (ហេព្រើរ ១១:៦)

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា មានព្រះតែមួយអង្គគត់ដែលជាព្រះដ៏ពិត និងបរិសុទ្ធយ៉ាងអស់កល្បជានិច្ច ហើយព្រះអង្គគឺជាព្រះអាទិករដែលមានគ្រប់ព្រះចេស្តា និងព្រះដែលថ្កោលទោសដ៏យុត្តិធម៌របស់យើង ហើយថាយើងក៏មានទំនួលខុសត្រូវជាមួយនឹងព្រះអង្គដែរ? តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 52 16/11/2021 08:57:27 AM

# ចេញពីដំណើររឿងនៃព្រះគម្ពីរអំពីសេចក្ដីសង្ឃឹម

## មនុស្ស

### អ្វីដែលយើងរៀនបានអំពីមនុស្ស៖

១. ព្រះជាម្ចាស់បានបង្កើតមនុស្សមកក្នុងលក្ខណៈពិសេស គឺក្នុងរូបអង្គទ្រង់។ ក្នុងលក្ខណៈនេះ យើងក៏ទទួលបានលក្ខណសម្បត្តិ និងសមត្ថភាពមួយចំនួនដែលរបស់សព្វសារពើផ្សេងៗទៀតរបស់ព្រះជាម្ចាស់មិនបានទទួល។
២. លក្ខណសម្បត្តិ និងសមត្ថភាពដ៏ពិសេសមួយចំនួនទាំងនេះបាននាំឲ្យយើងអាចធ្វើជាអ្នកមើលខុសត្រូវនៅលើការបង្កើតរបស់ព្រះជាម្ចាស់ ដែលនេះគឺជាតួនាទីមួយដែលព្រះជាម្ចាស់បានប្រគល់ដល់យើង។
៣. ព្រះជាម្ចាស់ស្រឡាញ់មនុស្សគ្រប់ៗរូប ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យយើងមានការប្រកបគ្នាដ៏ល្អឥតខ្ចោះជាមួយនឹងព្រះអង្គ ក៏ដូចជាមានអំណរក្នុងព្រះវត្តមានរបស់ទ្រង់ផងដែរ។
៤. ព្រះជាម្ចាស់មិនគ្រាន់តែបានប្រទានទូវទំនួលខុសត្រូវ និងសមត្ថភាពក្នុងការស្ដាប់បង្គាប់ទ្រង់ប៉ុណ្ណោះនោះទេ ប៉ុន្តែព្រះអង្គក៏ថែមទាំងប្រទានដល់យើងនូវសមត្ថភាពក្នុងការមិនស្ដាប់បង្គាប់ផងដែរ។
៥. ដោយសារព្រះជាម្ចាស់បានបង្កើតយើង ហើយយើងជាកម្មសិទ្ធិរបស់ទ្រង់ នោះមនុស្សគ្រប់ៗរូបមានទំនួលខុសត្រូវចំពោះព្រះអង្គ។
៦. ព្រះជាម្ចាស់បានបង្កើតមនុស្សយើងដោយមានវត្ថុធាតុខាងឯរូបកាយ ក៏ដូចជាមិនមានវត្ថុធាតុខាងឯព្រលឹងផងដែរ។
៧. ព្រលឹងមនុស្សនឹងមិនដែលសាបសូន្យនោះទេ គឺវានឹងបន្តរស់នៅយ៉ាងអស់កល្បជានិច្ចក្នុងរូបកាយដែលព្រះជាម្ចាស់នឹងប្រោសឲ្យរស់ឡើងវិញ។

**តើសេចក្ដីពិតមួយណាអំពីមនុស្សដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




២

**ព្រះគម្ពីរបានចែងថា៖** *ព្រះយេហូវ៉ាដ៏ជាព្រះបានយកធូលីដីមកសូនធ្វើជាមនុស្សហើយព្រះអង្គផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះគេ នោះមនុស្សក៏មានជីវិតរស់ឡើង។ (លោកុប្បត្តិ ២:៧)*

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថាព្រះជាម្ចាស់បានបង្កើតយើងមក ព្រះជាម្ចាស់ស្រឡាញ់យើង ហើយថាព្រះអង្គស័ក្តិសមក្នុងការទទួលការស្ដាប់បង្គាប់របស់យើង។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 53 16/11/2021 08:57:30 AM

# សេចក្ដីពិតសំខាន់៨យ៉ាងដែលកើត

## អំពើបាប

**អ្វីដែលយើងរៀនបានអំពីការមិនស្ដាប់បង្គាប់ព្រះជាម្ចាស់៖**

១. ព្រះជាម្ចាស់បានបង្កើត ស្រឡាញ់ និងផ្គត់ផ្គង់ដល់លោក អ័ដាម និងនាង អេវ៉ា ប៉ុន្តែពួកគេបានបះបោរទាស់ប្រឆាំងនឹងព្រះអង្គ។

២. ពួកគេមិនបានស្ដាប់បង្គាប់ព្រះអង្គ ហើយក៏បានបរិភោគផ្លែឈើពីដើមឈើតែមួយដើមដែលព្រះអង្គបានហាមមិនឲ្យពួកគេបរិភោគពីវា។

៣. ការមិនស្ដាប់បង្គាប់ព្រះជាម្ចាស់គឺហៅថាជា «*អំពើបាប*» ហើយគឺជាអំពើបាបដែលជាបទល្មើសយ៉ាងធ្ងន់ធ្ងរចំពោះព្រះជាម្ចាស់ ដែលជាព្រះដ៏ល្អឥតខ្ចោះ និងបរិសុទ្ធ។

៤. អំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា បានបង្ខូចទំនាក់ទំនងដ៏ល្អឥតខ្ចោះដែលពួកគាត់មានជាមួយនឹងព្រះជាម្ចាស់ និងជាមួយគ្នានិងគ្នា ហើយជាលទ្ធផលការនេះក៏នាំមកនូវការបំផ្លាស់បំប្រែសម្រាប់មនុស្សទាំងអស់ក្នុងរបៀបដ៏អាក្រក់ខាងឯសាច់ឈាម និងខាងឯព្រលឹងវិញ្ញាណ។

៥. មនុស្សទាំងអស់ទទួលជាមរតកនូវអំពើបាប និងលក្ខណៈនៃការបះបោររបស់ពួកគាត់។ ជម្លោះ សង្គ្រាម ភាពអាត្មានិយម និងអំនួតគឺជាលទ្ធផលទាំងអស់នៃការបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ក្នុងដួងចិត្តរបស់យើង។

៦. ព្រះគម្ពីរបានចែងថា យើងទាំងអស់គ្នាសុទ្ធតែធ្លាប់បានប្រព្រឹត្តអំពើបាប។ គ្រប់ៗគ្នាបានធ្វើនូវអ្វីដែលខ្លួនដឹងនៅក្នុងចិត្តថាមិនត្រឹមត្រូវ។

៧. ដោយសារព្រះជាម្ចាស់ជាអង្គដែលបរិសុទ្ធ ហើយថ្កោលទោសដ៏យុត្តិធម៌ ដូច្នេះអំពើបាបរបស់យើងនឹងមិនអាចរំលងផុតដោយគ្មានការដាក់ទារុណកម្មបានឡើយ។

**តើសេចក្ដីពិតមួយណាអំពីអំពើបាបដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




៣ **ព្រះគម្ពីរបានចែងថា៖** *ព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អរបស់ព្រះ។* (រ៉ូម ៣:២៣)

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា យើងបានប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហើយស័ក្តិសមនឹងទទួលទារុណកម្មដ៏សុចរិតរបស់ព្រះអង្គ។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 54 16/11/2021 08:57:31 AM

# ចេញពីដំណើររឿងនៃព្រះគម្ពីរអំពីសេចក្តីសង្ឃឹម

## សេចក្តីស្លាប់

**អ្វីដែលយើងរៀនបានអំពីទារុណកម្ម សម្រាប់អំពើបាប៖**

១. ការបែកបាក់គឺជាចំណុចស្នូលនៃសេចក្តីស្លាប់
២. រំពេចនោះនៅពេលដែលលោក អ័ដាម និងនាង អេវ៉ា បានប្រព្រឹត្តអំពើបាប នោះពួកគាត់ក៏បានស្លាប់ខាងឯព្រលឹងវិញ្ញាណ (គឺការបែកបាក់ចេញពីព្រះជាម្ចាស់)។
៣. ក្នុងនាមជាកូនចៅរបស់ពួកគាត់ មនុស្សទាំងអស់គ្នាក៏បានកើតមកដោយស្លាប់ខាងឯព្រលឹងវិញ្ញាណដែរ។
៤. ការស្លាប់ខាងឯសាច់ឈាមកើតឡើងនៅពេលដែលព្រលឹងមនុស្សបែកចេញពីរូបកាយ។ លោក អ័ដាម និងនាង អេវ៉ា ក៏បានទទួលបទពិសោធន៍នៃការស្លាប់ខាងឯសាច់ឈាម ដូច្នេះកូនចៅទាំងអស់របស់គាត់ក៏នឹងឆ្លងកាត់បទពិសោធន៍នេះដែរ។
៥. ការស្លាប់ខាងឯសាច់ឈាមមិនមែនជាចំណុចចុងក្រោយនៃការមានជីវិតរបស់មនុស្សយើងនោះទេ។ បន្ទាប់ពីបុគ្គលណាម្នាក់ស្លាប់ នោះគាត់នឹងទៅបង្ហាញមុខចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ដែលជាព្រះដ៏បរិសុទ្ធ និងថ្កោលទោសយ៉ាងយុត្តិធម៌លើមនុស្សទាំងអស់។
៦. តែអស់អ្នកណាដែលមិនព្រមទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះជាម្ចាស់សម្រាប់អំពើបាប និងសេចក្តីស្លាប់នឹងទទួលបទពិសោធន៍នៃការស្លាប់រដ៏នៅអស់កល្បជានិច្ចតាមរយៈ ការបែកចេញពីព្រះជាម្ចាស់ក្នុងដាក់ទារុណកម្មដោយដឹងខ្លួនដ៏នៅអស់កល្បជានិច្ច។
៧. ក្នុងសេចក្តីស្លាប់ រាល់គ្រប់ទម្រង់ទាំងអស់របស់វា គឺជាការថ្កោលទោសដ៏យុត្តិធម៌របស់ព្រះជាម្ចាស់សម្រាប់អំពើបាប។

**តើសេចក្តីពិតមួយណាអំពីការដាក់ទារុណកម្មសម្រាប់អំពើបាបដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




៤

**ព្រះគម្ពីរបានចែងថា៖** *ហើយដោយព្រោះបានតម្រូវឲ្យមនុស្សលោកទាំងអស់ស្លាប់ម្តង រួចមកត្រូវទទួលការជំនុំជម្រះយ៉ាងណា។ (ហេព្រើរ ៩:២៧)*

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា យើងកំពុងតែប្រឈមមុខនឹងការថ្កោលទោសរបស់ព្រះជាម្ចាស់ ហើយក៏មិនអាចគេចចេញពីការនោះដោយខ្លួនឯងបានដែរ។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?




The Story Translaated In Khmer -15.02.2021-Ro 3.0.indd 55
16/11/2021 08:57:31 AM

# សេចក្ដីពិតសំខាន់៨យ៉ាងដែលកើត

## ព្រះគ្រីស្ទ

**អ្វីដែលយើងរៀនបានអំពីព្រះយេស៊ូវគ្រីស្ទ៖**

១. មិនយូរប៉ុន្មានបន្ទាប់ពីលោក អ័ដាម និងនាង អេវ៉ា បានប្រព្រឹត្តអំពើបាប នោះព្រះជាម្ចាស់ក៏បានសន្យាថានឹងចាត់នរណាម្នាក់ឲ្យមក ដើម្បីយកឈ្នះលើសាតាំង។
២. បន្តិចម្ដងៗ ពាសពេញព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់ក៏បានបើកសម្ដែងថាបុគ្គលនេះជានរណា ហើយថាតាមរយៈការសុគតរបស់ទ្រង់ នោះព្រះអង្គនឹងប្រទានការអត់ទោសដល់អស់អ្នកដែលទុកចិត្តលើទ្រង់។
៣. ក្នុងការបំពេញសេចក្ដីសន្យារបស់ទ្រង់ នោះព្រះជាម្ចាស់ក៏បានចាត់ព្រះរាជបុត្រារបស់ព្រះអង្គគឺព្រះយេស៊ូវ ដើម្បីឲ្យមករំដោះយើងចេញពីការថ្កោលទោស។
៤. ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ក៏បានប្រសូតមកតាមរយៈស្ត្រីក្រមុំព្រហ្មចារីម្នាក់ដែលមានឈ្មោះថានាង ម៉ារា ហើយយើងក៏ស្គាល់ទ្រង់ថាព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែត។
៥. ព្រះយេស៊ូវបានគង់នៅដោយមានព្រះជន្មយ៉ាងល្អឥតខ្ចោះទាំងស្រុង ក្នុងការស្រឡាញ់ និងការស្ដាប់បង្គាប់ព្រះជាម្ចាស់។
៦. ក្នុងកំឡុងពេលនៃការធ្វើព័ន្ធកិច្ចរបស់ទ្រង់នៅលើផែនដីនេះ ព្រះយេស៊ូវបានបង្ហាញយ៉ាងច្បាស់លាស់ និងម្ដងហើយម្ដងទៀតតាមរយៈការអះអាង និងការអស្ចារ្យរបស់ទ្រង់ថា ព្រះអង្គគឺជាព្រះ។
៧. ក្នុងនាមជាព្រះ និងមនុស្សក្នុងបុគ្គលតែមួយដ៏ល្អឥតខ្ចោះ នោះព្រះយេស៊ូវគឺពិតជាពិសេស ហើយក៏ជាផ្លូវតែមួយគត់ទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ចមែន។

**តើសេចក្ដីពិតមួយណាអំពីព្រះយេស៊ូវគ្រីស្ទដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




៥

**ព្រះគម្ពីរបានចែងថា៖** *ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»។*
( យ៉ូហាន ១៤:៦ )

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះជាម្ចាស់ដ៏ល្អឥតខ្ចោះ ហើយក៏ជាកូនមនុស្សដ៏ល្អឥតខ្ចោះ និងជាផ្លូវតែមួយគត់ទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 56 16/11/2021 08:57:32 AM

# ចេញពីដំណើររឿងនៃព្រះគម្ពីរអំពីសេចក្តីសង្ឃឹម

## ឈើឆ្កាង

**អ្វីដែលយើងរៀនបានអំពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ៖**

១. ដោយសារព្រះជាម្ចាស់គឺជាព្រះដ៏បរិសុទ្ធល្អឥតខ្ចោះ ដូច្នេះដាច់ខាតព្រះអង្គត្រូវតែដាក់ទារុណកម្មលើអស់អ្នកដែលមិនស្តាប់បង្គាប់បទបញ្ញត្តិរបស់ទ្រង់។

២. ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង ទោះបើថាយើងប្រព្រឹត្តអំពើបាបក៏ដោយ នោះព្រះអង្គក៏ប្រទានសេចក្តីមេត្តាករុណា និងព្រះគុណរបស់ទ្រង់មកកាន់យើងតាមរយៈការផ្តត់ផ្តង់របៀបដ៏យុត្តិធម៌មួយដែលតាមរយៈការនោះយើងអាចទទួលបានការអត់ទោស។

៣. ក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានបង្កើតរបនាសម្ព័ន្ធនៃការថ្វាយយញ្ញបូជា ដែលតាមរយៈការនោះ មនុស្សមានបាបអាចទទួលបានការអត់ទោសពីអំពើបាបរបស់ខ្លួនបាន។

៤. បន្ទាប់មក ព្រះជាម្ចាស់ក៏បានចាត់ព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវដែលជាអង្គដ៏ល្អឥតខ្ចោះ ហើយក៏ជាយញ្ញបូជាចុងក្រោយសម្រាប់នូវរាល់អំពើបាបទាំងអស់ផងដែរ។

៥. ដោយសារអ្នកដឹកនាំសាសនា និងនយោបាយស្អប់ព្រះយេស៊ូវ ដូច្នេះពួកគេក៏បញ្ឆេះបញ្ឆូលមនុស្សម្នា ហើយបត់បែនក្រឹត្យវិន័យ ដើម្បីថ្កោលទោសព្រះអង្គឲ្យសុគត។

៦. ព្រះយេស៊ូវក៏បានស្ម័គ្រព្រះទ័យក្នុងការសុគតជំនួសយើងនៅលើឈើឆ្កាង ក្នុងនាមជាកូនចៀមនៃយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់យើងពីព្រះជាម្ចាស់ និងជាការបង់ថ្លៃលោះម្តងជាស្រេចសម្រាប់អំពើបាបទាំងអស់របស់យើង។

៧. បីថ្ងៃក្រោយមក ព្រះយេស៊ូវក៏បានមានព្រះជន្មរស់ពីការសុគតឡើងវិញជាថ្មីម្តងទៀត ដែលការនេះបង្ហាញថាព្រះជាម្ចាស់ទទួលយកយញ្ញបូជារបស់ព្រះយេស៊ូវថាជាការបង់ថ្លៃលោះដ៏សុចរិតសម្រាប់អំពើបាបរបស់យើង។

**តើសេចក្តីពិតមួយណាអំពីការសុគតរបស់ព្រះយេស៊ូវដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសចំណាំលើមួយឬពីរ។*




៦

**ព្រះគម្ពីរបានចែងថា៖** *ព្រះអង្គបានផ្ទុកអំពើបាបរបស់យើងក្នុងព្រះកាយព្រះអង្គ ដែលជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានស្លាប់ខាងឯអំពើបាប ហើយរស់ខាងឯសេចក្តីសុចរិត។ អ្នករាល់គ្នាបានជាសះស្បើយ ដោយសារស្នាមរបួសរបស់ព្រះអង្គ។ (១ពេត្រុស ២:២៤)*

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា ព្រះយេស៊ូវគ្រីស្ទដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់បានសុគតសម្រាប់អំពើបាបរបស់យើង ហើយក៏បានមានព្រះជន្មរស់ឡើងវិញពីការសុគតដើម្បីរំដោះយើងចេញពីការស្លាប់ និងប្រទានមកកាន់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 57 16/11/2021 08:57:32 AM

# សេចក្តីពិតសំខាន់៨យ៉ាងដែលកើត

## ជំនឿ

### អ្វីដែលយើងរៀនបានអំពីការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ៖

១. ក្នុងលក្ខណៈផ្ទុយគ្នាពីសាសនាផ្សេងៗលើផែនដីនេះ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទប្រទានទូវសេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ចក្នុងរបៀបដែលមិនតម្រូវឲ្យមនុស្សម្នាធ្វើការ ដើម្បីទទួលបានវាឡើយ។

២. ក្នុងនាមជាមនុស្ស មិនមានបុគ្គលណាម្នាក់អាចទិញសេចក្តីសង្គ្រោះបាន សូម្បីតែប្រសិនបើគាត់ចង់ ហើយព្យាយាមយកចិត្តទុកដាក់ធ្វើខ្លាំងប៉ុណ្ណាក៏ដោយ។

៣. តាមរយៈការសុគតនៃព្រះរាជបុត្រារបស់ទ្រង់ដែលជាព្រះយេស៊ូវ ព្រះដ៏ពេញដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិតបានប្រទានទូវផ្លូវមួយក្នុងការបង់ថ្លៃលោះសម្រាប់បំណុលនៃអំពើបាបរបស់យើង។

៤. ដោយសារព្រះយេស៊ូវបានបង់ថ្លៃលោះសម្រាប់ទារុណកម្មនៃអំពើបាបរបស់យើង នោះព្រះជាម្ចាស់ក៏ប្រទានសេចក្តីសង្គ្រោះដោយឥតគិតថ្លៃដល់យើងជាអំណោយទាន។

៥. ព្រះជាម្ចាស់បានសន្យាថា ទ្រង់អត់ទោសដល់យើងប្រសិនបើយើងកែប្រែចិត្ត ហើយទទួលជឿ ( ទុកចិត្ត ) លើព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ។

៦. ការកែប្រែចិត្តកើតឡើងនៅពេលដែលទស្សនៈខុសឆ្គងពីមុនៗរបស់យើងអំពីព្រះជាម្ចាស់ អំពីខ្លួនឯង និងអំពីអំពើបាបបានទទួលការបំផ្លាស់បំប្រែយ៉ាងជ្រាលជ្រៅដោយត្រាប់តាមទស្សនៈរបស់ព្រះជាម្ចាស់វិញ។

៧. ការជឿគឺជាការទុកចិត្តលើព្រះយេស៊ូវ ( ការដាក់ជំនឿរបស់យើងលើព្រះយេស៊ូវ ) ហើយមានតែព្រះយេស៊ូវតែមួយអង្គគត់ដែលអាចសង្គ្រោះយើងបាន។

**តើសេចក្តីពិតមួយណាអំពីការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




៧

**ព្រះគម្ពីរបានចែងថា៖** *ដ្បិតដោយសារព្រះគុណ អ្នករាល់គ្នាបានសង្គ្រោះតាមរយៈជំនឿ ហើយសេចក្តីនេះមិនមែនមកពីអ្នករាល់គ្នាទេ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ដើម្បីកុំឲ្យអ្នកណាម្នាក់អួតខ្លួន។* ( អេភេសូរ ២:៨-៩ )

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា យើងត្រូវតែទុកចិត្តលើការសុគតរបស់ព្រះយេស៊ូវនៅឯឈើឆ្កាងថាជាការបង់ថ្លៃលោះតែមួយគត់ដែលនាំឲ្យមានការស្កប់ស្កល់ព្រះហឫទ័យសម្រាប់អំពើបាបរបស់យើង ខណៈពេលដែលយើងបោះបង់ចោលទំនុកចិត្តនានាដែលយើងធ្លាប់មានពីមុនៗក្នុងការរំពឹងថាទ្រង់នឹងសង្គ្រោះយើង។ តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 58 16/11/2021 08:57:32 AM

# ចេញពីដំណើររឿងនៃព្រះគម្ពីរអំពីសេចក្ដីសង្ឃឹម

## ជីវិត

**អ្វីដែលយើងរៀនបានអំពីជីវិតដ៏នៅអស់កល្បជានិច្ច៖**

១. នៅពេលដែលយើងកែប្រែចិត្ត ហើយទុកចិត្តលើព្រះយេស៊ូវ នោះយើងនឹងឈានចេញពីការស្លាប់ខាងព្រលឹងវិញ្ញាណ ហើយឈានចូលទៅក្នុងការមានជីវិតខាងឯព្រលឹងវិញ្ញាណវិញ។

២. ជីវិតដ៏នៅអស់កល្បជានិច្ចខាងឯព្រលឹងវិញ្ញាណដែលព្រះជាម្ចាស់បានសន្យានឹងក្លាយជាបច្ចុប្បន្នកាលរបស់យើង ហើយក៏ជាកម្មសិទ្ធិដ៏នៅអស់កល្បជានិច្ចរបស់យើង ដោយមិនអាចបាត់បង់បានដែរ។

៣. ជាលទ្ធផល៖ ជីវិតខាងព្រលឹងវិញ្ញាណរបស់យើងនឹងមានសេចក្ដីប្រាថ្នា និងមានការជំរុញថ្មីដែលមានដូចជាការស្រឡាញ់ ការស្ដាប់បង្គាប់ ការថ្វាយបង្គំ និងការបម្រើព្រះជាម្ចាស់ចេញពីដួងចិត្តរបស់យើង។

៤. ទំនាក់ទំនងថ្មីរបស់យើងជាមួយនឹងព្រះជាម្ចាស់រំដោះយើងឲ្យមានសេរីភាពចេញពីការភ័យខ្លាចនៃសេចក្ដីស្លាប់ ដោយដឹងថាឈ្មោះរបស់យើងត្រូវបានសរសេរចុះក្នុងបញ្ជីជីវិតនៃកូនចៀម ហើយថាសេចក្ដីស្លាប់នាំយើងចូលទៅកាន់ព្រះវត្តមានរបស់ព្រះជាម្ចាស់។

៥. ឥឡូវនេះ យើងមានសមត្ថភាពក្នុងការទទួលបានបទពិសោធន៍នៃការស្រឡាញ់ អំណរ និងការបំពេញដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងមាន។

៦. ជីវិតយើងមានអំណរយ៉ាងអស់កល្បជានិច្ចក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់នៅឯស្ថានបរមសុខដែលជាទីកន្លែងដ៏ស្រស់ស្អាត គ្មានអំពើបាប និងគ្មានការឈឺចាប់ ព្រោះទីនោះគឺជាផែនដីថ្មីដែលទទួលបានការស្ដារឡើងវិញយ៉ាងល្អឥតខ្ចោះ។

៧. គឺមានតែនៅពេលនោះឯងដែលយើងនឹងយល់បានយ៉ាងពេញទីនូវចំណុចសំខាន់នៃដំណើររឿងនៃសេចក្ដីសង្ឃឹមរបស់ព្រះគម្ពីរបាន។

**តើសេចក្ដីពិតមួយណាអំពីជីវិតដ៏នៅអស់កល្បជានិច្ចដែលលោកអ្នកចង់យល់បន្ថែមទៀត?**

*ក្នុងចំណោមលេខទាំងនេះ សូមគូសរង្វង់ចំណាំលើមួយឬពីរ។*




៨

**ព្រះគម្ពីរបានចែងថា៖** *ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំជាសេចក្ដីរស់ឡើងវិញ និងជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ អ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ។ តើនាងជឿសេចក្ដីនេះឬទេ?»*
(យ៉ូហាន ១១:២៥-២៦)

**ការឆ្លើយតបខាងឯជំនឿរបស់យើង៖**
ចេញពីព្រះគម្ពីរ យើងបានសិក្សាថា មានតែព្រះយេស៊ូវមួយអង្គគត់ដែលមានអំណាចលើសេចក្ដីស្លាប់ ហើយថា ព្រះអង្គប្រទានជីវិតដ៏នៅអស់កល្បជានិច្ចចំពោះអ្នកដែលទុកចិត្តលើព្រះអង្គតែមួយអង្គគត់សម្រាប់ការទទួលបានការអត់ទោសនៃអំពើបាប តើលោកអ្នកជឿលើចំណុចនេះដែរឬទេ?



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 59 16/11/2021 08:57:33 AM

# ការឆ្លើយតបដោយមានជំនឿផ្ទាល់ខ្លួន

## យ៉ូហាន ៣:១៦-១៨



១៦ ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រា
ទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺ
ឲ្យមានជីវិតអស់កល្បជានិច្ចវិញ ១៧ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់
ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ
ដោយសារទ្រង់វិញ ១៨ ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ តែ
អ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាម
នៃព្រះរាជបុត្រាតែ១របស់ព្រះ។

*សូមសរសេរពាក្យពេចន៍ជាផ្ទាល់ខ្លួនលើកណ្ឌគម្ពីរ យ៉ូហាន ៣:១៦-១៨។ សូមប្តូរ «អ្នកណា» ទៅជាឈ្មោះរបស់លោកអ្នកក្នុងកថាខណ្ឌបន្ទាប់ ដែលយើងបានសម្រាយអំពីសេចក្តីសន្យាដ៏អស្ចារ្យនេះ។*

១៦ ដ្បិតព្រះស្រឡាញ់ ___________ ជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គ ដើម្បីឲ្យ ___________ ដែលជឿដល់ព្រះរាជបុត្រានោះ
មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ ១៧ ព្រោះព្រះមិនបាន
ចាត់ព្រះរាជបុត្រារបស់ព្រះអង្គ ឲ្យមកក្នុង ___________ ដើម្បីដាក់ទោស
___________ នោះទេ គឺឲ្យ ___________ បានសង្គ្រោះ ដោយសារព្រះអង្គ
វិញ។ ១៨ ___________ ដែលជឿដល់ព្រះអង្គ មិនជាប់មានទោសឡើយ តែ
___________ដែលមិនជឿវិញ មានទោសស្រេចទៅហើយ ព្រោះមិនបានជឿដល់
ព្រះនាមព្រះរាជបុត្រាតែមួយរបស់ព្រះ។

ឥឡូវនេះ ខ្ញុំយល់ឃើញថា ព្រះនៃព្រះគម្ពីរគឺជាព្រះដ៏ពិតតែមួយអង្គគត់។ ព្រះអង្គល្អឥតខ្ចោះ ហើយបរិសុទ្ធ។

តាមរយៈការបង្រៀននៃព្រះគម្ពីរ ឥឡូវនេះខ្ញុំមើលឃើញថាខ្លួនឯងមានលក្ខណៈខុសគ្នាជាងដូចដែលខ្ញុំធ្លាប់មើលឃើញពីមុនៗ។ ឥឡូវនេះ ខ្ញុំយល់ឃើញថា ខ្ញុំបានកើតមកដោយមានលក្ខណៈក្នុងអំពើបាប ហើយថាខ្ញុំក៏មិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ម្តងហើយម្តងទៀតដែរ ហើយថាអំពើបាបរបស់ខ្ញុំបានធ្វើឲ្យព្រះជាម្ចាស់ ដែលបានបង្កើតខ្ញុំមក ហើយស្រឡាញ់ខ្ញុំខកព្រះទ័យយ៉ាងខ្លាំងក្រៃលែង។ ខ្ញុំដឹងថា អំពើបាបរបស់ខ្ញុំបានបំបែកបំបាក់ខ្ញុំចេញពីព្រះជាម្ចាស់ ហើយថាការដាក់ទារុណកម្មដ៏សុចរិតសម្រាប់អំពើបាបរបស់ខ្ញុំគឺការបែកចេញដ៏នៅអស់កល្បជានិច្ចពីព្រះអង្គនៅកន្លែងដ៏ពិត ដែលមានការធ្វើបាបដែលព្រះគម្ពីរហៅថា «*ស្ថាននរក*»។

ខ្ញុំយល់ថា ការសុគត និងការមានព្រះជន្មរស់ឡើងវិញនៃព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលជាព្រះយេស៊ូវគ្រីស្ទគឺជាសេចក្តីសង្ឃឹមតែមួយគត់សម្រាប់ខ្ញុំក្នុងការទទួលបានការអត់ទោស ដើម្បីឱ្យខ្ញុំអាចគេចផុតចេញពីការដាក់ទារុណកម្មដ៏នៅអស់កល្បជានិច្ចសម្រាប់អំពើបាបរបស់ខ្ញុំ និងដើម្បីឲ្យខ្ញុំអាចទទួលបានអំណោយទាននៃជីវិតដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់បាន។

ឥឡូវនេះ ខ្ញុំទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ និងការសុគតរបស់ព្រះអង្គលើឈើឆ្កាង នឹងមិនមែននៅលើនរណាម្នាក់ ឬក៏អ្វីមួយផ្សេងទៀតឡើយ ថាជាការព្យាបាលតែមួយគត់ដែលគ្រប់គ្រាន់សម្រាប់បញ្ហានៃអំពើបាបរបស់ខ្ញុំ និងផលកម្មនានាដ៏អាក្រក់របស់វាដែរ។



The Story Translaated In Khmer -15.02.2021-Ro 3.0.indd 60 16/11/2021 08:57:40 AM

# ជំហាន
# បន្ទាប់

ជាមួយនឹងការផ្សាយដំណឹងល្អ និងការបង្កើតសិស្សរបស់ក្រុម Good Soil




Good Soil
Evangelism & Discipleship

# ការបង្កើតមូលដ្ឋានគ្រឹះនៃការបង្កើតសិស្សនៃគ្រីស្ទបរិស័ទ




## វិធីអំណរ

### ការសង្វាតដេញតាមជំហានមូលដ្ឋាននៃការបង្កើតសិស្ស

គោលបំណងចម្បងនៃកូនសៀវភៅនៃការណែនាំសម្រាប់អ្នកដឹកនាំក្នុងការសិក្សាគឺសម្រាប់ជាការប្រើប្រាស់ក្នុងការសិក្សាបែបបន្តលើការបង្កើតសិស្សនៃការផ្សាយដំណឹងល្អ។ គោលបំណងចម្បងនៃការប្រើប្រាស់របស់វាគឺសម្រាប់រៀនបែបជាវគ្គមួយទល់នឹងមួយក្នុងការបង្កើតសិស្ស។ ទោះជាយ៉ាងណាក៏ដោយក៏លោកអ្នកអាចប្រើប្រាស់វាក្នុងបរិបទក្នុងក្រុមតូច ឬក៏ប្រើប្រាស់កូនសៀវភៅសិក្សាក្នុងថ្នាក់រៀនសម្រាប់អ្នកជឿថ្មីថ្មោង។ កូនសៀវភៅនេះមានមេរៀន១០ជំពូក និងក្រដាសរឹងមួយដុំដែលមាន២គម្ពីចងចាំ ដើម្បីជាការប្រើប្រាស់ក្នុងការភ្ជាប់មេរៀន។



## ជំហានមូលដ្ឋានក្នុងការដើរតាមព្រះយេស៊ូវ

### សូមចាប់ផ្ដើមជំហានមូលដ្ឋានរបស់លោកអ្នកក្នុងការដើរតាមព្រះយេស៊ូវ

មេរៀនទី១៖ ការរម្លឹក «ដំណើររឿងនៃសេចក្ដីសង្ឃឹម»
មេរៀនទី២៖ ការរម្លឹក «ស្ពាននៃជីវិតដែលរៀបតាមកាល»
មេរៀនទី៣៖ ការធានា & សុវត្ថិភាពនៃសេចក្ដីសង្គ្រោះ
មេរៀនទី៤៖ ព្រះគម្ពីរ
មេរៀនទី៥៖ ការអធិស្ឋាន
មេរៀនទី៦៖ ព្រះវិញ្ញាណបរិសុទ្ធ
មេរៀនទី៧៖ ភាពបរិសុទ្ធផ្ទាល់ខ្លួន
មេរៀនទី៨៖ ការធ្វើបន្ទាល់
មេរៀនទី៩៖ ពួកជំនុំតាមតំបន់
មេរៀនទី១០៖ ផែនការរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នក



www.GoodSoil.com/Resources

# សៀវភៅ & សំឡេងសម្រាប់សិក្សាព្រះគម្ពីរ




## ការសញ្ជឹងគិត លើដំណើររឿងនៃសេចក្តីសង្ឃឹមរបស់ព្រះជាម្ចាស់

*ការសញ្ជឹងគិតលាតត្រដាងដំណើររឿងនៃព្រះគម្ពីរតាមរយៈព្រឹត្តិការណ៍៥០ពីព្រះគម្ពីរសញ្ញាចាស់ និងព្រឹត្តិការណ៍៥០ពីព្រះគម្ពីរសញ្ញាថ្មី ដោយមានការរៀបរៀងឡើងតាមរយៈ២៥សម័យកាលចម្បងៗនៃព្រះគម្ពីរចេញពីកណ្ឌគម្ពីរលោកុប្បត្តិដល់កណ្ឌគម្ពីរវិវរណៈ។ ដោយមានប្រមាណលើសជាង២០០ទំព័រ (៩" x ១២") និងរូបភាពពេញនៃព្រឹត្តិការណ៍ព្រះគម្ពីរប្រមាណជាង១០០ទំព័រ។ នេះគឺជាសៀវភៅរឿងព្រះគម្ពីរសម្រាប់មនុស្សគ្រប់គ្នា៖ យុវជន កូនក្មេង គ្រីស្ទបរិស័ទ ឬក៏មិនមែនជាគ្រីស្ទបរិស័ទ។*

## ការសញ្ជឹងគិត៖ បទពិសោធន៍សំឡេង

ការថតបែបជាអាជីពនៃការនិទានរឿងទាំង១០០រឿងចេញពីសៀវភៅ «*ការសញ្ជឹងគិតលើដំណើររឿងនៃសេចក្តីសង្ឃឹមរបស់ព្រះជាម្ចាស់*» បែបជាដំណើរសំឡេង (៦ ១/២ ម៉ោងសរុប) ក្នុងដំណើររឿងនៃការប្រោសលោះបែបជារូបភាពធំនៃព្រះគម្ពីរចាប់ពីកណ្ឌគម្ពីរលោកុប្បត្តិដល់កណ្ឌគម្ពីរវិវរណៈ។ ដំណើររឿងជាសំឡេងមានរួមទាំងសាច់ភ្លេង សំឡេងដែលគួរឲ្យចាប់អារម្មណ៍ និងសំឡេងរំភើបៗពីសំឡេងតារាៗជាអាជីពប្រមាថជាង២០នាក់។ ជម្រើស៣៖ យកសំឡេងជា MP3 ទាញយកសំឡេង MP3 ឬក៏ប្រើប្រាស់កម្មវិធីលើទូរស័ព្ទដៃដែលមានរួមទាំងរូបភាព (ការសញ្ជឹងគិត៖ បទពិសោធន៍សំឡេងដែលអាចមើលឃើញ)







www.GoodSoil.com/Resources

# ចំណេះដឹងព្រះគម្ពីរឲ្យកាន់តែស៊ីជម្រៅ




## **ឫសគល់នៃជំនឿ៖** ការស្រាវជ្រាវព្រះគម្ពីរពីដើមដល់ចប់

*«ឫសគល់នៃជំនឿ»* គឺជាការសិក្សាអំពីដំណើររឿងនៃការប្រោសលោះនៃព្រះគម្ពីរដែលមានលក្ខណៈទូលំទូលាយ (ព្រឹត្តិការណ៍ព្រះគម្ពីរ១០០) និងការយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ (៨០ម៉ោងនៃការចូលរួមក្នុងថ្នាក់រៀន)។ កម្មវិធីសិក្សាព្រះគម្ពីរដែលរៀបតាមកាលមានរួមទាំងមេរៀនពីរថ្នាក់រៀន៖ **ឫសគល់នៃជំនឿ—ព្រះគម្ពីរសញ្ញាចាស់ និងឫសគល់នៃជំនឿ—ព្រះគម្ពីរសញ្ញាថ្មី។**

***«ឫសគល់នៃជំនឿ—ព្រះគម្ពីរសញ្ញាចាស់»*** លាតត្រដាងសេចក្តីសន្យានានានៃព្រះមេស្ស៊ីនៃសាសន៍យូដាដែលនឹងក្លាយជាព្រះអង្គសង្គ្រោះនៃលោកីយ៍នេះ។

***«ឫសគល់នៃជំនឿ—ព្រះគម្ពីរសញ្ញាថ្មី»*** បកស្រាយការបំពេញសេចក្តីសង្ឃឹម និងសេចក្តីសន្យានៃព្រះគម្ពីរសញ្ញាចាស់ ដោយមានមូលដ្ឋានលើព្រះជន្មដ៏ល្អឥតខ្ចោះ និងការសុគតជាយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ។

www.GoodSoil.com/Roots